# ការគ្រោងថវិកា

១. ស្មើរទាំងអស់នៃសកម្មភាព ត្រូវការតែពេលវេលាប៉ុណ្ណោះ

២. សកម្មភាពដែលត្រូវការចំណាយថវិកា គឺ ជាសកម្មភាពដែលរកចំណូល ដូចជា កម្មវិធីបំណិនរកចំណូល និងចំណាយដោយស្មាតស្មំ «សាលារកចំណូល គ្រូនិងនាយករកចំណូល សិស្សរកចំណូល និងចំណាយដើម្បីប្រជាជន សិស្ស និងសហគមន៍»

៣. កុំចំណាយលុយដែលមិនមានចំណូល

៤. ចំណាយរដ្ឋបាល ត្រូវតែអនុវត្តក្នុងបរិបទ រកចំណូល  ដូចជា កុំចាយទិញក្រដាសដើម្បីទិញក្រដាស

76

# ផែនការលទ្ធផលឆ្នាំ២០២៣ បឋមសិក្សា និងមធ្យមសិក្សា

# សាលាមានស្តង់ដា និងសាលាថ្មី

100




101

បឋមសិក្សា ឬមធ្យមសិក្សា គំរូផែនការកែលម្អសាលារៀន និងថវិកា ឆ្នាំ២០២២ (ផែនការលទ្ធផល ពិន្ទុស្តង់ដា ទំព័រ ៤៩)ឈ្មោះសាលារៀនៈ ក្ដុងៈ ឈ្មោះនាយកសាលារៀនៈ លេខទូរស័ព្ទ
ភូមិៈ ឃុំៈ ស្រុកៈ ខេត្តៈ

**តារាងពិន្ទុស្តង់ដាសហគមន៍សាលារៀន តាមស្តង់ដានិមួយៗ និងស្តង់ដាសរុបសហគមន៍សាលារៀន ឆ្នាំ២០៣**

| ពិន្ទុអប្បបរមា | ស្តង់ដាទី១ ៣៩ | | ស្តង់ដាទី២ ៤៨ | | ស្តង់ដាទី៣ ៤៨ | | ស្តង់ដាទី៤ ៤៨ | | ស្តង់ដាទី៥ ២៧ | | សរុបពិន្ទុ២១០ | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ដើមឆ្នាំ | ចុងឆ្នាំ | ដើមឆ្នាំ | ចុងឆ្នាំ | ដើមឆ្នាំ | ចុងឆ្នាំ | ដើមឆ្នាំ | ចុងឆ្នាំ | ដើមឆ្នាំ | ចុងឆ្នាំ | ដើមឆ្នាំ | ចុងឆ្នាំ |
| ពិន្ទុ២០២៣ | 0 | 13 | 0 | 16 | 0 | 16 | 0 | 16 | 0 | 9 | 0 | 70 |
| ពិន្ទុ២០២៤ | 13 | 26 | 16 | 32 | 16 | 32 | 16 | 32 | 9 | 18 | 70 | 140 |
| ពិន្ទុ២០២៥ | 26 | 39 | 32 | 48 | 32 | 48 | 32 | 48 | 18 | 27 | 140 | 210 |
| ពិន្ទុ២០២៦ | | | | | | | | | | | | |
| ពិន្ទុ២០២៧ | | | | | | | | | | | | |
| | | | | | | | | | | | | |

102

# សរសេរកិច្ចការ១៖ អ្នកធ្វើ កិច្ចការ ពេលវេលា

- សាលា ពិនិត្យបញ្ជីឈ្មោះកុមារតាមអាយុ នៅខែវិច្ឆិកា ឆ្នាំ២០២២ (មើលរបៀបធ្វើនៅក្នុងឯកសារ)
- ក្រុមការងារ ចុះដល់ផ្ទះសិស្ស នៅសប្តាហ៍ទី១ ខែ មករា ២០២៣ (មើលរបៀបធ្វើនៅក្នុងឯកសារ)

103

| លេខ | ស្តង់ដានិងសូចនាករ | ពិន្ទុ១ | ពិន្ទុ២ | ពិន្ទុ៣ | ពិន្ទុ៤ |
|---|---|---|---|---|---|
| ស្តង់ដាទី១៖ សាលារៀនដំណើរការសម្រាប់ផលសម្រេចការអប់រំនិងការសិក្សារបស់សិស្ស (ទិន្នន័យយេនឌ័រនៅគ្រប់សូចនាករ) | | | | | |
| ១ | ចំនួននិងភាគរយសិស្សចូលរៀន | >៩០% | >៩៥% | >៩៧% | >៩៩% |

គ្រប់សូចនាករ មានពិន្ទុដើមឆ្នាំ 0 និងពិន្ទុគ្រោងចុងឆ្នាំនេះ គឺ ១។ <u>សកម្មភាពក្នុងឆ្នាំ៖</u>

១ សហការជាមួយក្រុមប្រឹក្សាឃុំសង្កាត់ និងប្រធានភូមិ ក្នុងការពិនិត្យបញ្ជីឈ្មោះកុមារ៧២ខែ ដល់អាយុត្រូវចូលរៀននៅបឋមសិក្សា និងសិស្សបឋមសិក្សាជាក់ស្តែងម្តង ម្នាក់ៗកំពុងរៀនថ្នាក់ទី១ដល់៦។ ផ្តល់ព័ត៌មានដល់មាតាបិតាចុះឈ្មោះចូលរៀនថ្នាក់ទី១ ជាមួយនឹងសិស្សចាស់ពីឆ្នាំមុន នៅសាលាបឋមសិក្សា យ៉ាងយូរត្រឹមថ្ងៃទី២០ ខែធ្នូ នៃឆ្នាំ សិក្សា។ ចំពោះគ្រួសារចំណាកស្រុកមករស់នៅទីតាំងថ្មី សាលារៀនត្រូវកត់ត្រាទិន្នន័យកុមារឬសិស្សទាំងអស់ និងជម្រាបមាតាបិតានាំកូនមកចុះឈ្មោះចូលរៀន សាលារៀនមិនត្រូវទារឯកសារគ្រួសារឬសំបុត្រកំណើតទេ ព្រោះថាគាត់មិនមានឯកសារនេះទេ ម្យ៉ាងវិញទៀតសាលារៀនដាច់ខាតមិនត្រូវទារលុយពីមាតាបិតាសម្រាប់ការចុះឈ្មោះនេះឡើយ។

២ នៅអាទិត្យបន្ទាប់ពីថ្ងៃចុះឈ្មោះចូលរៀន ប្រសិនមិនឃើញសិស្សណាម្នាក់មកចុះឈ្មោះទេ សាលារៀននឹងចាត់តំណាងចុះដល់ផ្ទះសិស្ស ពិភាក្សាជាមួយមាតាបិតា ឬ អ្នកអាណាព្យាបាល ផ្តល់សម្ភារៈសិក្សាដល់សិស្ស ឱ្យគេចុះឈ្មោះក្នុងបញ្ជីចុះឈ្មោះចូលរៀននៅផ្ទះសិស្ស និងផ្តាំផ្ញើឱ្យគេទៅរៀននៅថ្ងៃបន្ទាប់។

៣ អនុវត្តការធ្វើតេស្តស្តង់ដាវាយតម្លៃសមត្ថភាពសិស្ស និងធ្វើការបិទផ្សាយលទ្ធផលតេស្តជាសាធារណៈ។

៤ គណៈកម្មការគ្រប់គ្រងសាលារៀនបញ្ចូលទិន្នន័យជាលទ្ធផលពីការធ្វើតេស្តស្តង់ដាចូលក្នុងតារាងសរុបលទ្ធផលតេស្តដើមឆ្នាំ ថ្នាក់ទី១ ចុងឆ្នាំសម្រាប់ថ្នាក់ទី២ ដល់ទី៦

104

<table>
<tr><th colspan="6">ផែនការសកម្មភាពឆ្នាំ ២០២២</th></tr>
<tr><td>លេខ</td><td>ស្តង់ដានិងសូចនាករ</td><td>ពិន្ទុ១</td><td>ពិន្ទុ២</td><td>ពិន្ទុ៣</td><td>ពិន្ទុ៤</td></tr>
<tr><td colspan="6">ស្តង់ដាទី១ សាលារៀនដំណើរការសម្រាប់ផលសម្រេចការអប់រំនិងការសិក្សាសិស្ស (ទិន្នន័យយេនដ័រនៅគ្រប់សូចនាករ)</td></tr>
<tr><td>១</td><td>ចំនួននិងភាគរយសិស្សចូលរៀន</td><td>>៩០%</td><td>>៩៥%</td><td>>៩៧%</td><td>>៩៩%</td></tr>
<tr><td colspan="6">ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សកម្មភាពក្នុងឆ្នាំ:<br>១ សហការណ៍ជាមួយសាលាបឋមសិក្សាចំណុះទាំងអស់ ក្នុងការពិនិត្យបញ្ជីឈ្មោះសិស្សនិងពិនិត្យសិស្សជាក់ស្តែងម្តងម្នាក់ៗកំពុងរៀនថ្នាក់ទី៦។ ផ្តល់ព័ត៌មានដល់សិស្សថ្នាក់ទី៦ មុនដាច់ឆ្នាំសិក្សា ថាត្រូវមកជាមួយមាតាបិតាចុះឈ្មោះចូលរៀនថ្នាក់ទី៧នៅសាលាមធ្យមសិក្សាឈ្មោះអី នៅថ្ងៃទី ២០ ខែធ្នូនៃឆ្នាំ។<br>២ នៅអាទិត្យបន្ទាប់ពីថ្ងៃចុះឈ្មោះចូលរៀន ប្រសិនមិនឃើញសិស្សណាម្នាក់មកចុះឈ្មោះទេ សាលារៀននឹងចាត់មនុស្សចុះដល់ផ្ទះសិស្ស ពិភាក្សាជាមួយមាតាបិតាឬយាយតាផ្តល់សម្ភារៈសិក្សាដល់សិស្ស ឲ្យគេចុះឈ្មោះក្នុងបញ្ជីចុះឈ្មោះចូលរៀននៅផ្ទះសិស្ស និងផ្តាំផ្ញើឲ្យគេទៅរៀននៅថ្ងៃបន្ទាប់។<br>៣ អនុវត្តការធ្វើតេស្តស្តង់ដាវាយតម្លៃសមត្ថភាពសិស្ស និងធ្វើការបិទផ្សាយលទ្ធផលតេស្តជាសាធារណៈ។<br>៤ គណៈកម្មការគ្រប់គ្រងសាលារៀនបញ្ចូលទិន្នន័យជាលទ្ធផលពីការធ្វើតេស្តស្តង់ដាចូលក្នុងតារាងសរុបលទ្ធផលតេស្តដើមឆ្នាំថ្នាក់ទី៧និងចុងឆ្នាំសម្រាប់ថ្នាក់ទី៨ដល់ទី១២។</td></tr>
</table>

105

<table>
<tr><td>២</td><td>ចំនួននិងភាគរយសិស្សបោះបង់ការសិក្សា</td><td>>៣%</td><td>៣%</td><td>១-២%</td><td><១%</td></tr>
<tr><td colspan="6">ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សកម្មភាពក្នុងឆ្នាំ:<br>១ នៅពេលមានសិស្សណាអវត្តមាន សាលារៀននឹងចាត់មនុស្សចុះដល់ផ្ទះសិស្ស ពិភាក្សាជាមួយមាតាបិតាឬយាយតា ដោះស្រាយបញ្ហាកំពុងមាន និងផ្តាំផ្ញើឲ្យសិស្សទៅរៀននៅថ្ងៃបន្ទាប់។ ជៀសវាងដាច់ខាតនូវការបន្តអវត្តមាន ពិសេសមិនឲ្យលើសពី៤ដង។ សាលារៀនមិនអនុញ្ញាតិឲ្យសិស្សណាអវត្តមាន ក្រៅពីមានមូលហេតុឈឺពិតប្រាកដនោះទេ។</td></tr>
<tr><td>៣</td><td>ចំនួននិងភាគរយសិស្សឡើងថ្នាក់</td><td><៩៥%</td><td><៩៦%</td><td>=<៩៨%</td><td>>៩៨%</td></tr>
<tr><td colspan="6">ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សកម្មភាពក្នុងឆ្នាំ:<br>១ សាលារៀននឹងឲ្យសិស្សទាំងអស់ឡើងថ្នាក់ និងពុំទុកឲ្យសិស្សណាម្នាក់ត្រួតថ្នាក់ទេ។ តែសាលារៀននិងគ្រូបង្រៀនត្រូវធ្វើផែនការសាលារៀននិងថ្នាក់រៀនជួយសិស្សឲ្យរៀនតាមទាន់កម្មវិធីសិក្សានៃថ្នាក់ដែលសិស្សកំពុងរៀន។ គ្រូបង្រៀនត្រូវសហការគ្នាតាមជួយសិស្សរហូត៣ទៅ៦ឆ្នាំ ពោលគឺពីថ្នាក់ទី៧រហូតដល់ថ្នាក់ទី១២ ធានាថាគេអាចរៀនបានដល់កម្រិតយ៉ាងហោចបាននីទ្ទេសល្អ។<br>សាលារៀននិងគ្រូបង្រៀនប្តេជ្ញាចិត្តជួយសិស្សតាមវិធីខាងក្រោម៖ ក. ជួយរៀនបន្ថែមអានអក្សរ ពីកម្រិតសមត្ថភាពរបស់គេដែលបង្ហាញដោយតេស្តវិនិច្ឆ័យ ជាមួយការ អានតាម ប្រព័ន្ធអានអក្សរឥន្ទនូ អានឃ្លា អានល្បឿន ប្រកួតប្រជែងអាន ខ. ផ្តល់អត្ថបទឱ្យសិស្សអាននៅផ្ទះឬនៅក្រៅថ្នាក់រៀន គ. ដាក់លំហាត់ឱ្យសិស្សធ្វើនៅផ្ទះ គ្រូកែលំហាត់និងជួយសិស្សរៀនបំពេញបន្ថែម ខ. គ្រូមិនយកលុយពីសិស្សក្រីក្រទេ តែសាលារៀនជួយពិភាក្សាជាមួយមាតាបិតាក្នុងថ្នាក់ ដើម្បីស្វែងរកការជួយឧបត្ថម្ភពីគ្រួសារមានលទ្ធភាព ដើម្បីជួយសិស្សក្រីក្រ ត. សាលារៀនមានមូលនីធិជាចំណូលពីកម្មវិធីបំណិន អាចយកមូលនីធិមកជួយគ្រូបង្រៀនបាន</td></tr>
</table>

106

| | | | | | |
|---|---|---|---|---|---|
| ៤ | ចំនួននិងភាគរយសិស្សមាននិទ្ទេសA និង Bមុខវិជ្ជាភាសាខ្មែរ | =<១៩% | ២០%-២៩% | ៣០%-៣៩% | ៤០%-៥០% (២០និង៣០) |
| ៥ | ចំនួននិងភាគរយសិស្សមាននិទ្ទេសA និងBមុខវិជ្ជាគណិតវិទ្យា | =<១៩% | ២០%-២៩% | ៣០%-៣៩% | ៤០%-៥០% (២០និង៣០) |
| ៦ | ចំនួននិងភាគរយសិស្សមាននិទ្ទេសមធ្យមឡើងមុខវិជ្ជារូបវិទ្យា (A, B, C) | <១៩% | ២០%-៣៩% | ៤០%-៥៩% | ៦០%-៨០% (20/30/30) |
| ៧ | ចំនួននិងភាគរយសិស្សមាននិទ្ទេសមធ្យមឡើងមុខវិជ្ជាគីមីវិទ្យា(A, B, C) | <១៩% | ២០%-៣៩% | ៤០%-៥៩% | ៦០%-៨០% (20/30/30) |
| ៨ | ចំនួននិងភាគរយសិស្សមាននិទ្ទេសមធ្យមឡើងមុខវិជ្ជាជីវវិទ្យា(A, B, C) | <១៩% | ២០%-៣៩% | ៤០%-៥៩% | ៦០%-៨០% (20/30/30) |
| ៩ | ចំនួននិងភាគរយសិស្សមាននិទ្ទេសមធ្យមឡើងមុខវិជ្ជាប្រវត្តិវិទ្យា(A, B, C) | <១៩% | ២០%-៣៩% | ៤០%-៥៩% | ៦០%-៨០% (20/30/30) |

ក) សូចនាករទី៤ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ ខ) សូចនាករទី៥ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សូចនាករទី៦ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សូចនាករទី៧ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សូចនាករទី៨ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សូចនាករទី៩ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។

សកម្មភាពក្នុងឆ្នាំ:

១ នៅពេលប្រជុំដើមឆ្នាំសិក្សា ក្រោយពីការរៀបចំផែនការកែលម្អប្រចាំឆ្នាំហើយ នាយកសាលានិងគគសឬកបស កោះអញ្ជើញសហគមន៍ទាំងអស់មកប្រជុំដើមឆ្នាំសិក្សា។ គគស ឬនាយកសាលប្រកាសពីបេសកកម្ម គោលបំណង និងផែនការកែលម្អសាលារៀន និងសំណើរសិស្ស មាតាបិតាសិស្ស សហគមន៍ទាំងអស់ចូលរួមសហការពេញទំហឹងជាមួយសាលារៀននិងគ្រូបង្រៀន ជួយសិស្សរៀនមានសមត្ថភាពមុខវិជ្ជា បំណិនរកចំណូលនិងរកចំណូលបាន ព្រមទាំងសាលារៀនជួយសិស្សឲ្យក្លាយជាមនុស្សល្អក្នុងសហគមន៍។ សាលារៀនត្រូវយកពង្រាងផែនការសាលារៀនទៅពិគ្រោះយោបល់ជាមួយប្រជាជននៅតាមភូមិ កែលម្អផែនការតាមមតិយោបល់ប្រជាជន និងបិទផ្សាយផែនការជាសាធារណៈ។



| | | | | | |
|---|---|---|---|---|---|
| ១០ | ចំនួននិងភាគរយសិស្សថ្នាក់ទី៧មានសមត្ថភាពអានតាមស្តង់ដា( ១០០ទៅ ១២០ពាក្យក្នុងមួយនាទី ) | >៤៥% | >៦០% | >៧៥% | >៨០% |
| ១១ | ចំនួននិងភាគរយសិស្សថ្នាក់ជាតិទី៩មានសមត្ថភាពអានតាមស្តង់ដា( ២០០ទៅ ២៥០ពាក្យក្នុងមួយនាទី ) | >៤៥% | >៦០% | >៧៥% | >៨០% |

សូចនាករទី១០ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សូចនាករទី១១ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សកម្មភាព:

១ រៀបចំការប្រកួតប្រជែងល្បឿនអំណាន និងធ្វើលំហាត់គណិតវិទ្យា សម្រាប់សាលារៀនខ្លួនឯង ឬជាមួយសាលារៀនក្នុងស្រុកឬខេត្ត ឬជាមួយសាលារៀនឯកជន។ បញ្ចូលថ្ងៃ ខែ ឆ្នាំនៃការព្រមព្រៀងប្រកួតប្រជែងជាមួយសាលារៀនផ្សេង។ ការប្រកួតប្រជែងនេះត្រូវអនុវត្តជាប់ជាប្រចាំខែ ត្រីមាស វាស់វែងការរីកចម្រើន និងភាពជោគជ័យនៃការសិក្សា។

| | | | | | |
|---|---|---|---|---|---|
| ១២ | ចំនួននិងភាគរយសិស្សប្រឡងជាប់ការប្រឡងថ្នាក់ជាតិទី៩ | >60% | >70% | >80% | >90% |
| ១៣ | ចំនួននិងភាគរយសិស្សប្រឡងជាប់ការប្រឡងថ្នាក់ជាតិទី១២ | >60% | >70% | >80% | >90% |

ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សកម្មភាព:

១ ក្រសួងនឹងផ្តល់សំនួរតេស្តជាស្តង់ដាពីក្រសួង (មានកម្រិតងាយ មធ្យម និងលំបាក តាមកម្រិតតេស្តអន្តរជាតិ) ហើយរដ្ឋបាលនៃការប្រឡងត្រូវមានភាពគ្រប់គ្រងប្រជ្រោយតាមការណែនាំ។

២ លទ្ធផលប្រឡងនឹងត្រូវបញ្ជូនទៅក្រសួងសម្រាប់ធ្វើការវិភាគ ផលិតរបាយការណ៍ និងត្រូវមានព័ត៌មានត្រឡប់មកសាលារៀនវិញនៅពេលរៀបចំសិក្ខាសាលាពីយុទ្ធសាស្ត្រសហគមន៍សាលារៀនជារៀងរាល់ឆ្នាំ។

| | | | | | |
|---|---|---|---|---|---|
| | សរុបពិន្ទុស្តង់ដាទី១ | ១៣ | ២៦ | ៣៩ | ៤២ |
| | សរុបពិន្ទុជាក់ស្តែងនៅចុងឆ្នាំសិក្សាចំនួន (សរុបពិន្ទុពីកូឡោនខាងស្តាំទាំង៤) | ១៣ | | | |

| ស្តង់ដាទី២ ថ្នាក់រៀនដំណើរការសម្រាប់ការបង្រៀន និងរៀននៃសិស្សម្នាក់ៗ | | | | | |
|---|---|---|---|---|---|
| ១ | ចំនួនថ្នាក់រៀនមានផែនការបង្រៀន៣ឆ្នាំតាមមុខវិជ្ជា | >៨៥% | >៩០% | >៩៥% | =/<១០០% |
| ២ | ចំនួនថ្នាក់រៀនមានផែនការបង្រៀនប្រចាំឆ្នាំតាមមុខវិជ្ជា | >៨៥% | >៩០% | >៩៥% | =/<១០០% |

សូចនាករទី១ ពិន្ទុដើមឆ្នាំ( ជាពិន្ទុចុងឆ្នាំមុន ) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ  XX។ សូចនាករទី២ ពិន្ទុដើមឆ្នាំ( ជាពិន្ទុចុងឆ្នាំមុន ) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។

សកម្មភាពៈ

១ គ្រូទទួលបន្ទុកថ្នាក់ ប្រជុំនៅចុងខែធ្នូ នៃឆ្នាំ មុនចាប់ចូលបវេសនកាល ជាមួយគ្រូមុខវិជ្ជាទាំងអស់ និងសិស្សទាំងអស់នៃថ្នាក់។ យកក្រុមគោលដៅឆ្នាំបច្ចុប្បន្ននៃផែនការផលសម្រេចអប់រំនិងការសិក្សា៣ឆ្នាំជាគោល សម្រាប់ធ្វើផែនការបង្រៀន៣ឆ្នាំតាមមុខវិជ្ជា រួចបន្តរៀបចំផែនការបង្រៀនប្រចាំឆ្នាំតាមមុខវិជ្ជា។

២ សិស្សម្នាក់ៗត្រូវរៀបចំផែនការរៀនសូត្ររបស់ខ្លួន ដោយមានការជួយពីសិស្សរួមថ្នាក់បើត្រូវការ។ *ផែនការរៀនសូត្ររបស់សិស្សត្រូវមាន កម្រិតផលសម្រេចពីការរៀនសូត្រ ដែលសរុបសិស្សទាំងអស់មានចំនួនស្មើគ្នានឹងផែនការបង្រៀនប្រចាំឆ្នាំតាមមុខវិជ្ជារបស់ថ្នាក់រៀន។* ដូចនេះពេលសិស្សទាំងអស់រៀបចំផែនការរៀនសូត្រហើយនោះ គ្រូទទួលបន្ទុកថ្នាក់ និងគ្រូបង្រៀនមុខវិជ្ជាត្រូវបូកសរុបទិន្នន័យពីផែនការរៀនសូត្រសិស្សម្នាក់ៗ និង*ត្រូវឲ្យមានភាពស៊ីគ្នានឹងផែនការបង្រៀនប្រចាំឆ្នាំរបស់ថ្នាក់រៀន និងតាមមុខវិជ្ជា។*

109

| | | | | | |
|---|---|---|---|---|---|
| ៣ | ចំនួនមុខវិជ្ជាមានបំណែងចែកកម្មវិធីសិក្សាបង្រៀនប្រចាំសប្តាហ៍ និងកាលវិភាគបង្រៀនលម្អិតតាមមេរៀន | =/<៦ | ៧-៨ | ៩-១០ | ១១-១២ |
| ៤ | ចំនួនមុខវិជ្ជាថ្នាក់ទី៧ដល់១២មានប្លង់មេរៀនតាមគ្រប់មេរៀន | ៦ | ៧-៨ | ៩-១០ | ១១-១២ |
| ៥ | ចំនួនថ្នាក់រៀនមានផែនការបង្រៀន៣ខែ | >៨៥% | >៩០% | >៩៥% | =/<១០០% |

សូចនាករទី៣ ពិន្ទុដើមឆ្នាំ ( ជាពិន្ទុចុងឆ្នាំមុន ) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ  XX។ សូចនាករទី៤ ពិន្ទុដើមឆ្នាំ ( ជាពិន្ទុចុងឆ្នាំមុន ) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ  XX។ សូចនាករទី៥ ពិន្ទុដើមឆ្នាំ ( ជាពិន្ទុចុងឆ្នាំមុន ) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ  XX។

សកម្មភាពៈ

១ បន្ទាប់ពីការប្រជុំខាងលើ គ្រូទទួលបន្ទុកថ្នាក់ប្រជុំជាមួយគ្រូមុខវិជ្ជា រៀបចំ បំណែងចែកកម្មវិធីសិក្សាបង្រៀនប្រចាំសប្តាហ៍ និងកាលវិភាគបង្រៀនលម្អិតតាមមេរៀន  ប្លង់មេរៀនតាមគ្រប់មេរៀន ផែនការបង្រៀន៣ខែ។ គ្រូទទួលបន្ទុកថ្នាក់ត្រូវបញ្ជូនផែនការទាំងអស់នេះទៅនាយកសាលារៀន។

២ នាយកសាលាត្រូវពិនិត្យផ្ទៀងផ្ទាត់ថាគ្រប់ថ្នាក់រៀន និងគ្រប់កម្រិតមានប្រភេទផែនការទាំងអស់ខាងលើ។

110

| | | | | | |
|---|---|---|---|---|---|
| ៦ | ចំនួនថ្នាក់រៀនមានការប្រជុំពិនិត្យតាមដានការរៀនសូត្រទៀងទាត់ | >៨៥% | >៩០% | >៩៥% | ១០០% |
| ៧ | ចំនួននិងភាគរយសិស្សមាននិងអនុវត្តការតាមដានផែនការសិក្សារៀនសូត្រប្រចាំឆ្នាំសិក្សា | >៨៥% | >៩០% | >៩៥% | ១០០% |

សូចនាករទី៦ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សូចនាករទី៧ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សកម្មភាព:

១ គ្រូទទួលបន្ទុកថ្នាក់ សម្របសម្រួល ក្នុងការបញ្ចូលទិន្នន័យពីការធ្វើតេស្តស្តង់ដាប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំចូលក្នុងតារាងដោយមានការជួយពីសិស្សនិងគ្រូបង្រៀន។

២ គ្រូទទួលបន្ទុកថ្នាក់ត្រូវដឹកនាំការប្រជុំទៀងទាត់ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ។ ប្រើលទ្ធផលពីតេស្តស្តង់ដា ពិភាក្សាជាមួយគ្រូបង្រៀន ព្រមជាមួយការព្រមព្រៀងជាមួយគ្រូបង្រៀនរៀបចំផែនការបង្រៀន៣ខែបន្ទាប់។

៣ សិស្សម្នាក់ៗបញ្ចូលទិន្នន័យតេស្តចូលក្នុងតារាងតាមដានការសិក្សារបស់ខ្លួន និងត្រូវប្រឹងប្រែងរៀនសូត្រតាមការណែនាំរបស់គ្រូនូវមុខវិជ្ជាណាដែលនៅរៀនយឺត។

៤ សិស្សម្នាក់ត្រូវអានអត្ថបទឬមេរៀនគ្រូប្រាប់ រួចឆ្លើយនឹងសំនួរ ឬមួយ ឆ្លើយនឹងសំនួរជ្រើសរើស ឬមួយ ដោះស្រាយចំណោទ។ សិស្សអាចសិក្សាគ្រប់ពេល និងនៅគ្រប់ទីកន្លែង។ សិស្សនឹងអាចប្រើ បច្ចេកវិទ្យា ក្នុងការរៀនសូត្រដោយខ្លួនឯងនេះ។

៥ គ្រូបង្រៀនត្រូវអនុវត្តតេស្តស្តង់ដានៅគ្រប់មេរៀនដែលបង្រៀន ធានាថាសិស្សទាំងអស់រៀនចេះ។ សាលារៀនត្រូវអនុវត្តតេស្តស្តង់ដាប្រចាំខែ សរុបលទ្ធផលតេស្ត វិភាគលទ្ធផលតេស្តនៅចុងខែរៀងរាល់ខែ ដោយធៀបជាមួយផែនការបង្រៀន៣ខែ និងឈានទៅធានាថាក្រុមគោលដៅចុងឆ្នាំនឹងត្រូវបានសម្រេច។

111

| | | | | | |
|---|---|---|---|---|---|
| ៦ | ចំនួនថ្នាក់រៀនមានការប្រជុំពិនិត្យតាមដានការរៀនសូត្រទៀងទាត់ | >៨៥% | >៩០% | >៩៥% | ១០០% |
| ៧ | ចំនួននិងភាគរយសិស្សមាននិងអនុវត្តការតាមដានផែនការសិក្សារៀនសូត្រប្រចាំឆ្នាំសិក្សា | >៨៥% | >៩០% | >៩៥% | ១០០% |

៦ គ្រូបង្រៀនត្រូវរៀបចំការប្រជុំជាមួយមាតាបិតាសិស្សនិងសិស្ស ពន្យល់ពីមេរៀនណាខ្លះដែលសិស្សនៅរៀនយឺត ពិភាក្សាកំណត់សកម្មភាពត្រូវអនុវត្តដើម្បីដោះស្រាយនូវមេរៀនដែលរៀនយឺត។ គ្រូបង្រៀនត្រូវបង្រៀនមេរៀនឡើងវិញប្រសិនសិស្សភាគច្រើនមិនចេះ មាតាបិតាត្រូវជួយកូនឲ្យរៀននៅផ្ទះតាមការណែនាំរបស់គ្រូ ឬមួយរៀននៅសាលាពេលល្ងាចនិងយប់បន្ថែម ហើយសិស្សត្រូវអានអក្សរឲ្យឮៗរហូតទោះនៅកន្លែងណាក៏ដោយ និងធ្វើលំហាត់តាមការណែនាំពីគ្រូ។

៧ ពិសេសសម្រាប់សិស្សដែលមាននិទ្ទេស D E F គ្រូបង្រៀនត្រូវពន្យល់មាតាបិតាថា កូនរបស់គាត់មានគម្លាតសមត្ថភាពតាំងពី៣ឬ៤ឆ្នាំមុន ដូចនេះគាត់ត្រូវរៀនបំពេញកម្លាតសមត្ថភាពទាំងនេះសិនមុននឹងគាត់អាចរៀនកម្មវិធីសិក្សានៃថ្នាក់ដែលគាត់កំពុងរៀន ដូចនេះសិស្សត្រូវរៀនបន្ថែមម៉ោងពេលយប់តាំងពីម៉ោង៦រហូតដល់ម៉ោង១០យប់ ដើម្បីឲ្យបានការសិក្សាសរុប១២ទៅ១៥ម៉ោងក្នុងមួយថ្ងៃទើបអាចរៀនទាន់។ ដើម្បីធ្វើការបង្រៀនបន្ថែមម៉ោងច្រើនដូចនេះបានលុះណាមាតាបិតាអាចជួយបង់ថ្លៃសិក្សាជាការស្ម័គ្រចិត្តដើម្បីគ្រូបង្រៀនអាចរៀបចំថ្នាក់ឲ្យសិស្សរៀនបាន។ ការបង់ថ្លៃមិនកំណត់ចំនួនទេ គ្រួសារអ្នកធូរធារអាចបង់ច្រើនតាមលទ្ធភាព តែគ្រួសារក្រីក្រអាចមិនបាច់បងឬមួយបង់តិចតួចតាមការដែលចង់រួមចំណែក។ ការបង់ថ្លៃត្រូវបង់ទៅនាយកសាលាឬគគស ហើយត្រូវទទួលបានវិញនូវវិក័យប័ត្រត្រឹមត្រូវ។

៨ សិស្សជាអ្នកកត់ត្រាចំនួនម៉ោងបង្រៀនបន្ថែម និងបញ្ជូនកំណត់ត្រាទៅនាយកសាលាឬគគសដើម្បីបើកប្រាក់ឧបត្ថម្ភមកគ្រូបង្រៀនវិញ។ សាលារៀនត្រូវធ្វើរបាយការណ៍ចំណូលចំណាយនៅដំណាច់ឆ្នាំសិក្សានិងបិទផ្សាយជាសាធារណៈ។

112

| | | | | | |
|---|---|---|---|---|---|
| ៨ | ចំនួននិងភាគរយសិស្សរៀនសូត្របំណិនកសិកម្មនិងបច្ចេកទេសដើម្បីរកចំណូល | >៥០% | >៦០% | >៧០% | =/>៨០% |
| ៩ | ចំនួនសិស្សបានធ្វើកិច្ចការគម្រោងទាំងអស់ | >៨៥% | >៩០% | >៩៥% | =/<១០០% |

សូចនាករទី៨ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សូចនាករទី៩ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សកម្មភាពៈ

១ នាយកសាលាពិភាក្សាជាមួយគគស និងព្រមព្រៀងគ្នាអនុវត្តកម្មវិធីនេះ។ ការអនុវត្តត្រូវប្រព្រឹត្តទៅតាមការណែនាំមាននៅក្នុងសៀវភៅនេះ។

២ សិស្សរៀនធ្វើកិច្ចការជាគម្រោង តាមការរៀនបែបចម្រុះមុខវិជ្ជា។ សិស្សនឹងមានសមត្ថភាពរកចំណូល រកចំណូលបាន និងអាចសន្សំលុយទៅរៀននៅមហាវិទ្យាល័យ។ទាំងអស់នេះមាននៅក្នុងសៀវភៅហើយ ៖

ក សាលារៀនប្រជុំជាមួយសិស្ស ណែនាំពីការរៀនធ្វើកិច្ចការជាគម្រោង តាមការណែនាំរបស់ក្រសួង កត់ឈ្មោះសិស្សនិងមុខបំណិនសិស្សម្នាក់ៗចង់រៀននិងអនុវត្ត ហើយសាលារៀនបញ្ជូនឈ្មោះសិស្សមកក្រសួង

ខ នាយកសាលារៀនដែលបានរៀនសូត្រពីមហាវិទ្យាល័យអប់រំ ធ្វើកិច្ចការជាមួយ គ្រូបង្រៀន ដែលបានរៀនសូត្រពីសាកលវិទ្យាល័យ បង្រៀនសិស្សពីការរៀនចំគម្រោងវិនិយោគ តាមមុខបំណិនសិស្សចង់រៀន បន្ទាប់សិស្សម្នាក់ៗរៀបចំគម្រោងវិនិយោគរបស់គ្រួសារ ប្រមូលសរុបទិន្នន័យនិងព័ត៌មានជាក្រុមសិស្សតាមភូមិ បញ្ជូនមកសាលារៀន បញ្ចប់សាលារៀនត្រូវប្រមូលសរុបគម្រោងវិនិយោគទាំងអស់ជាគម្រោងវិនិយោគរបស់សាលារៀន

113

| | | | | | |
|---|---|---|---|---|---|
| ៨ | ចំនួននិងភាគរយសិស្សរៀនសូត្របំណិនកសិកម្មនិងបច្ចេកទេសដើម្បីរកចំណូល | >៥០% | >៦០% | >៧០% | =/>៨០% |
| ៩ | ចំនួនសិស្សបានធ្វើកិច្ចការគម្រោងទាំងអស់ | >៨៥% | >៩០% | >៩៥% | =/<១០០% |

គ គ្រូបង្រៀន និងនាយកសាលារៀន បង្រៀនសិស្សពីបំណិន ទាំងទ្រឹស្តីនិងការអនុវត្ត សិស្សសិក្សាទ្រឹស្តី និងហាត់អនុវត្តមុខបំណិននៅសាលារៀន ព្រមទាំងសិក្សាខ្លឹមសារមុខវិជ្ជា បន្សីគ្នាទៅនឹងដំណាក់ការនៃការរៀនសូត្រមុខបំណិន ដូចមាននៅក្នុងការណែនាំ

ឃ សិស្ស បន្តរៀនសូត្រនិងអនុវត្តមុខបំណិននៅតាមផ្ទះ ឬកសិដ្ឋាន សម្រាប់បំណិនកសិកម្ម ឬរោងជាង សម្រាប់បំណិនកម្មន្តសាលកម្ម។ សិស្សរៀនកត់ត្រាទិន្នន័យ និង ព័ត៌មាន ជួបពិភាក្សាក្នុងក្រុម វិភាគការរីកចម្រើននិងបញ្ហាជួបប្រទះ និងរកសកម្មភាពជាដំណោះស្រាយបញ្ហាដែលបានលើកឡើង នាយកសាលានិងគ្រូបង្រៀន ចុះជួយសិស្សតាមផ្ទះសិស្សពិសេសសិស្សមានជួបបញ្ហាក្នុងការរៀនសូត្រនិងអនុវត្ត សិស្សបូកសរុបលទ្ធផលការរៀនសូត្រនិងយកមកបង្ហាញនៅសាលារៀន តាមត្រីមាស ឆមាស និងចុងឆ្នាំ

ច សាលារៀន បូកសរុបលទ្ធផល ត្រីមាស ឆមាស និងចុងឆ្នាំ ហើយបង្ហាញលទ្ធផលទៅសហគមន៍ នៅពេលបូកសរុបលទ្ធផលនិមួយៗ ហើយបន្តសកម្មភាពជាវដ្តវិលជុំឡើងវិញ

114

| | | | | | |
|---|---|---|---|---|---|
| ១០ | ចំនួនដងប្រកួតប្រជែងការអានអក្សរ | =/<៦ | ៦-៧ | ៨-៩ | >១០ |
| ១១ | ចំនួនដងប្រកួតប្រជែងការធ្វើលំហាត់គណិតវិទ្យា | =/<៦ | ៦-៧ | ៨-៩ | >១០ |

សូចនាករទី៨ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សកម្មភាព

១ ការប្រកួតប្រជែងនេះមានរៀបរាប់នៅក្នុងស្តង់ដាទី១ម្តងរួចហើយ។ ការបញ្ចូលសកម្មភាពដដែលនៅក្នុងស្តង់ដាទី ២ គឺ ជាការបញ្ជាក់នូវភាពសំខាន់ចាំបាច់ដែលមិនអាចខ្វះបាននៃសូចនាករនេះ ដូចនេះនាយកសាលារៀន និងគ្រូបង្រៀនត្រូវរៀបចំសកម្មភាពនេះជាប់ជាបន្ត និងទៀងទាត់រាល់ខែឬពីរខែម្តង។ បើសិស្សអាចអានតាមល្បឿនកំណត់ក្នុងមួយនាទី សិស្សនឹងអាចយល់អត្ថបទបាន សិស្សនឹងអាចរៀនគ្រប់មុខវិជ្ជាបាន សិស្សនិងអាច បណ្តុះសមត្ថភាពគិត វិភាគ និងសរសេរបាន ដូចនេះសិស្សអាចរៀនទៅមហាវិទ្យាល័យបាន។ គ្រូបង្រៀនគប្បីចងចាំនិងយល់ថា ការអានឮៗ ជាការចាំបាច់ ព្រោះវាជួយខួរក្បាលសិស្សឲ្យឮនិងចងចាំនូវពាក្យដែលគេអាន។ បើទោះជាអានអត្ថបទដដែលៗច្រើនដងតែជាការជួយឱ្យការអានកាន់តែលឿន នោះជាការចាំបាច់។

115

| | | | | | |
|---|---|---|---|---|---|
| ១២ | ចំនួននិងភាគរយសិស្សអវត្តមានលើស៤ដង | ២% | ១.៥% | ១.០% | ០៥% |
| ១៣ | ចំនួនដងគ្រូអវត្តមានមិនមានគ្រូជំនួស | <២០ | <១៥ | <១០ | <៥ |
| ១៤ | ចំនួនថ្ងៃសាលាបិទទ្វារមិនតាមការឈប់សម្រាកប្រចាំឆ្នាំរបស់រដ្ឋ | ៥ | ៣-៤ | ២ | ១ |

សូចនាករទី១២ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សូចនាករទី១៣ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សូចនាករទី១៤ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សកម្មភាព

១ សិស្សជាអ្នកកត់ត្រា សិស្សអវត្តមាន គ្រូអវត្តមាន គ្រូអវត្តមានត្រូវតែមានគ្រូជំនួស សាលាបិទទ្វាតែថ្ងៃឈប់សម្រាកកំណត់ដោយរដ្ឋ

២ សាលារៀនមិនត្រូវអនុញ្ញាតិឱ្យមានការរៀបចំពិធីក្នុងសាលារៀន ឬមួយ មានការផ្សាយពាណិជ្ជកម្មក្នុងសាលារៀន ឬមួយយកសិស្សទៅចូលរួមពិធីណាមួយដែលនាំឲ្យខាតបង់ម៉ោងសិក្សារៀនសូត្ររបស់សិស្ស។ ក្នុងករណីណាដែលមានការបង្ខំឲ្យធ្វើនូវរឿងរ៉ាវទាំងអស់នេះ គគសនិងនាយកសាលា ត្រូវរាយការណ៍មកក្រសួងសម្រាប់ធ្វើអន្តរាគមន៍ ហើយសាលារៀនមិនបាច់រវល់ជាមួយសំណើរទាំងនោះទេ គឺ នៅបន្តដំណើរការសាលារៀនដដែល។

៣ នាយកសាលាត្រូវកត់ត្រាព័ត៌មានទាំងនេះ ហើយបូកសរុប និងយកមកពិភាក្សានៅសិក្ខាសាលារៀងរាល់ឆ្នាំពីយុទ្ធសាស្ត្រសហគមន៍សាលារៀន។

116

| | | | | | |
|---|---|---|---|---|---|
| ១៥ | ចំនួននិងភាគរយសិស្សទួលរងចរិយាហឹង្សាពីគ្រូថយចុះរហូតដល់គ្មាននៅឆ្នាំទី១ | ១.៥% | ១.0% | 0.៥% | 0% |

សូចនាករទី១៥ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សកម្មភាព

១ សាលារៀនប្រមូលទិន្នន័យពីហឹង្សាក្នុងគ្រួសារ តាមថ្នាក់រៀន និងក្នុងសាលារៀនតាមគម្រូនៅក្នុងសៀវភៅនេះ។

២ នាយកសាលារៀន ជាមួយគគស គ្រូបង្រៀន និងសិស្ស រៀបចំផែនការបំបាត់អំពើហឹង្សានេះតាមគម្រូមាននៅក្នុងសៀវភៅនេះ។ គ្រូត្រូវសិក្សាពីករណីសិស្សមានហឹង្សានៅផ្ទះ យកលទ្ធផលសិក្សាមកបង្ហាញនៅថ្នាក់រៀននិងសាលារៀន ហើយជួយសិស្សដោះស្រាយបញ្ហាហឹង្សាជាមួយរដ្ឋអំណាច ជាមួយការជួយសិស្សរៀនសូត្រទាន់ថ្នាក់

៣ កត់ត្រានូវភាពរីកចម្រើននៃការថយចុះនូវអំពើហឹង្សានៅតាមផ្ទះ ចំពោះហឹង្សានៅក្នុងថ្នាក់រៀន និងសាលារៀន គឺ ត្រូវបញ្ឈប់ជាបន្ទាន់ និងមិនអនុញ្ញាតិឲ្យមានជាលើកទី ពីរ។ តំណាងសិស្សតាមថ្នាក់ត្រូវរាយការជាបន្ទាន់ដល់នាយកសាលាឬគគសប្រសិនគ្រូណាម្នាក់ប្រព្រឹត្តចរិយាហឹង្សាដល់សិស្ស។

៤ នាយកសាធានាថា មានការកត់ត្រានូវទិន្នន័យពីហឹង្សា និងបញ្ចូលទៅក្នុងការប្រជុំប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ដើម្បីពិភាក្សាដោះស្រាយ។



| | | | | | |
|---|---|---|---|---|---|
| ១៥ | ចំនួននិងភាគរយសិស្សទួលរងចរិយាហឹង្សាពីគ្រូថយចុះរហូតដល់គ្មាននៅឆ្នាំទី១ | ១.៥% | ១.0% | 0.៥% | 0% |

សូចនាករទី១៦ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សកម្មភាព

១ ជាមួយការណែនាំពីសាកលវិទ្យាល័យ នាយសាលារៀបចំប្រជុំជាមួយសិស្ស ដើម្បីរៀបចំនូវកម្មវិធីមុខរបរសម្រាប់សិស្សម្នាក់ៗតាមការណែនាំក្នុងសៀវភៅនេះ

២ សិស្សម្នាក់ត្រូវសម្រេចចិត្តថាត្រូវទៅរៀនមុខជំនាញអ្វីនៅមហាវិទ្យាល័យ ទៅតាមកោសល្យរបស់ខ្លួន ជាមួយភាពខ្លាំងលើមុខវិជ្ជានៅមធ្យមសិក្សា និងចុះឈ្មោះជាមួយសាកលវិទ្យាល័យដែលខ្លួនមានបំណងប្រាថ្នាទៅរៀន

៣ សាកលវិទ្យាល័យបន្តការជួយសិស្សអនុវត្តបំណិនកសិកម្មឬបច្ចេកទេសឲ្យបានត្រឹមត្រូវតាមបច្ចេកវិទ្យាទំនើប។

| | | | | | |
|---|---|---|---|---|---|
| | សរុបពិន្ទុស្តង់ដាទី២ | ១៦ | ៣២ | ៤៨ | ៦៤ |
| | សរុបពិន្ទុជាក់ស្តែងនៅចុងឆ្នាំសិក្សាចំនួន (សរុបពិន្ទុពីកូឡោនខាងស្តាំទាំង៤) | ១៦ | | | |

| | | | | | |
|---|---|---|---|---|---|
| ស្តង់ដាទី៣ ភាពជាម្ចាស់នៃសាលារៀនសហគមន៍ | | | | | |
| ១ | ចំនួននិងភាគរយគ្រួសារមានហិង្សា | ១.៥% | ១.០% | ០.៥% | ០% |
| ២ | ចំនួនសមាសសភាពគណៈកម្មការគ្រប់គ្រងសាលារៀន ឬក្រុមប្រឹក្សាសាលារៀន | <៧ | ៧-៨ | ៩-១០ | >១០ |
| ៣ | ការប្រជុំប្រចាំត្រីមាស ឆមាស និងឆ្នាំដែលដឹកនាំដោយគគស ឬគបស | ខែទៀងទាត់ | ត្រីមាសទៀងទាត់ | ឆ្នាំទៀងទាត់ | ទាំងអស់ |

សូចនាករទី១ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សូចនាករទី២ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សូចនាករទី៣ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សកម្មភាព

១ នាយកសាលារៀនរៀបចំប្រជុំ បោះឆ្នោតជ្រើសរើសគណៈកម្មការគ្រប់គ្រងសាលារៀនតាមការណែនាំ និងបញ្ជូនបញ្ជីឈ្មោះទៅស្រុកដើម្បីអនុម័ត

២ គគសដឹកនាំការប្រជុំប្រចាំត្រីមាស ឆមាស និងឆ្នាំតាមការណែនាំក្នុងសៀវភៅ។ សិស្ស គ្រូបង្រៀន និងនាយកសាលារៀនពិភាក្សាគ្នាពី សារៈសំខាន់នៃ ទិន្នន័យ ព័ត៌មាន និងស្ថិតិ (តាមការណែនាំ) ចាប់ផ្តើមកត់ទិន្នន័យ និងព័ត៌មាន ទៅតាមសូចនាករ ទាំងអស់នៃស្តង់ដានីមួយៗ ។ ប្រើប្រាស់ទិន្នន័យនិងព័ត៌មាន នៅក្នុងការប្រជុំប្រចាំខែ ពិនិត្យការអនុវត្តសកម្មភាព ប្រជុំប្រចាំត្រីមាសពិនិត្យការសម្រេចលទ្ធផលជាក្រុមគោលដៅត្រីមាស និងប្រជុំប្រចាំឆ្នាំពិនិត្យការសម្រេចលទ្ធផលជាក្រុមគោលដៅចុងឆ្នាំ។ ពេលប្រជុំនីមួយៗ ត្រូវរកឲ្យឃើញបញ្ហា ដែលនាំរាំងស្ទះ ការរៀនសូត្រ និងការបង្រៀន ហើយកំណត់សកម្មភាពជាក់ស្តែង ច្បាស់លាស់ សម្រាប់ដោះស្រាយបញ្ហា

៣ គគសដឹកនាំការប្រជុំប្រែក្លាយគគស ទៅជា ក្រុមប្រឹក្សាសាលារៀន នៅពេលណាដែលសាលារៀនមានការរីកចម្រើន ហើយមាន



| | | | | | |
|---|---|---|---|---|---|
| ៤ | ចំនួនគ្រូបង្រៀនបានទទួលការសម្រេចចិត្តពីគគសឬគសលើការវាយតម្លៃការអនុវត្តការងារប្រចាំឆ្នាំ | >៨០% | >៨៥% | >៩០% | =>៩០% |
| ៥ | ចំនួននាយកនិងនាយករងបានទទួលការសម្រេចចិត្តពីគគសឬគសលើការវាយតម្លៃការអនុវត្តការងារប្រចាំឆ្នាំ | ០ | ១ | ២-៣ | ទាំងអស់ |

សូចនាករទី៤ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សូចនាករទី៥ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។សកម្មភាព

១ នាយកសាលារៀនបង្ហាញពីលទ្ធផលវាយតម្លៃ គ្រូបង្រៀននិងនាយកសាលារៀន ប្រចាំឆ្នាំដល់គគស ហើយគគសពិភាក្សាជាមួយនាយកសាលារៀន កំណត់រង្វាន់ត្រូវផ្តល់ជូនគ្រូបង្រៀនណា និងអនុម័តរបាយការណ៍វាយតម្លៃ

២ ដោយឡែកសម្រាប់នាយកសាលារៀន និងនាយករងសាលារៀន គឺ គគស និងនាយកសាលារៀនត្រូវអនុវត្តការវាយតម្លៃតាមការណែនាំក្នុងសៀវភៅ ហើយចុងបញ្ចប់គគសសម្រេចអនុវត្តការវាយតម្លៃ កំណត់ពិន្ទុវាយតម្លៃ និងរង្វាន់ត្រូវផ្តល់ឲ្យ

៣ សាលារៀនត្រូវបញ្ជូន លទ្ធផលវាយតម្លៃ របស់គ្រូបង្រៀននិងនាយកសាលារៀន មកក្រសួង នៅដើមខែមករា រៀងរាល់ឆ្នាំ និងដាក់ស្នើសុំ ឋានៈវិជ្ជាជីវៈ ទៅតាមលទ្ធផលសម្រេចបាន របស់គ្រូបង្រៀន និងនាយកសាលារៀន។ ក្រសួងពិនិត្យ និងបូកសរុបលទ្ធផលជាមួយនិងសំណើររបស់សាលារៀន និងរាយាករណ៍ និងស្នើសុំ ឋានៈវិជ្ជាជីវៈដល់គ្រូបង្រៀន និងនាយកសាលារៀន។

| | | | | | |
|---|---|---|---|---|---|
| ៦ | ចំនួនសិស្សធ្លាក់បានមករៀនវិញទៀងទាត់ | >៩០% | >៩៥% | >៩៩% | ទាំងអស់ |

សូចនាករទី៦ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សកម្មភាព:

១ នាយកសាលារៀននិងគគសរៀបចំ និងចុះសួរសុខទុក្ខសិស្សអវត្តមានដល់ផ្ទះជាប់ជាបន្ត ពិភាក្សាជាមួយមាតាបិតាសិស្ស កំណត់អនុវត្តសកម្មភាពដោះស្រាយបញ្ហា និងនាំសិស្សមករៀនវិញ។

| | | | | | |
|---|---|---|---|---|---|
| ៧ | បរិមាណចំណូលមូលនីធិរបស់សាលារៀន | ២០០០០ | កើន២ទៅ៣ដង | កើន៤ដល់៦ដង | កើនលើស១០ដង |

សូចនាករទី៧ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សកម្មភាព

១ នាយកសាលារៀននិងគគសឬកបស ត្រូវគ្រោងថវិកាសរុបត្រូវការប្រចាំឆ្នាំ និងកំណត់បរិមាណចំណូលពីប្រភពមួយៗ នៅខែធ្នូ ឲ្យបានច្បាស់លាស់សម្រាប់អនុវត្តសកម្មភាពក្នុងផែនការកែលម្អសាលារៀន។

២ គ្រោងសកម្មភាព នៅខែធ្នូ ដែលត្រូវចំណាយបន្ថែមមាន:

ក) ការបង្រៀនបន្ថែមម៉ោងឲ្យបាន១៥ម៉ោងមួយថ្ងៃ

ខ) ការរៀបចំកសិដ្ឋានកសិកម្ម ឬរោងជាងនៅសាលារៀន និងអនុវត្តការរៀនសូត្របំណិនរកចំណូល

គ) ការរៀបចំថ្នាក់កុំព្យូទ័រ និងភាសាបរទេសដូចជា អង់គ្លេស ឬបារាំង ចិន ថៃ។ល។

ឃ) ការរៀបចំថ្នាក់មត្តេយ្យសិក្សានៅក្នុងសាលាបឋមសិក្សាឬមធ្យមសិក្សា

ង) ការរៀបចំកន្លែងលក់ដូរ អាហារដ្ឋាន និងភោជនីយដ្ឋាន ដែលជាទីតាំងរៀនសូត្របំណិនការងាររបស់សិស្ស

ច) ការរៀបចំកសិដ្ឋានឲ្យក្លាយជាទីតាំងទេសចរ ។ល។

121

| | | | | | |
|---|---|---|---|---|---|
| ៨ | ទិន្នន័យតេស្តវាយតម្លៃស្តង់ដាលើសមត្ថភាពសិស្សត្រូវបានអនុម័តនិងបិទផ្សាយ | តេស្តខែ | បូកត្រីមាស | បូកឆមាស | ទាំងអស់ |
| ៩ | ផែនការសកម្មភាពអនុវត្តសូចនាករគន្លឹះបានអនុម័តដោយគគសឬកបស | ផលិត | អនុម័តឆ្នាំទី១ | អនុម័តឆ្នាំទី២ | អនុម័តឆ្នាំទី៣ |
| ១០ | ផែនការកែលម្អសាលារៀននិងថវិកាប្រចាំឆ្នាំបានអនុម័តដោយគគសឬកបស | ផលិត | អនុម័តឆ្នាំទី១ | អនុម័តឆ្នាំទី២ | អនុម័តឆ្នាំទី៣ |
| ១១ | របាយការណ៍វាយតម្លៃស្តង់ដាសាលារៀនត្រូវបានអនុម័តដោយគគសឬកបស | ផលិត | អនុម័តឆ្នាំទី១ | អនុម័តឆ្នាំទី២ | អនុម័តឆ្នាំទី៣ |
| ១២ | របាយការណ៍ឆ្នាំត្រូវបានអនុម័តដោយគគសឬកបស | ផលិត | អនុម័តឆ្នាំទី១ | អនុម័តឆ្នាំទី២ | អនុម័តឆ្នាំទី៣ |
| ១៣ | ទិន្នន័យបិទផ្សាយជាសាធារណៈត្រូវបានអនុម័តដោយគកសឬគស និងបិទផ្សាយ | ផលិត | អនុវត្តឆ្នាំទី១ | អនុវត្តឆ្នាំទី២ | អនុវត្តឆ្នាំទី៣ |

សូចនាករទី៨ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សូចនាករទី៩ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សូចនាករទី១០ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សូចនាករទី១១ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សូចនាករទី១២ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សូចនាករទី១៣ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សកម្មភាព:

១ នាយកសាលារៀនជាអ្នកសម្របសម្រួលរៀបចំនូវការប្រជុំ និងដាក់ស្នើសំណុំឯកសារទាំងអស់ខាងលើមក គគស ឬ កបស ដើម្បីពិនិត្យ និងអនុម័ត។

២ នាយកសាលាធានានូវការបិទផ្សាយគ្រប់ទិន្នន័យ និងព័ត៌មានខាងលើជាសាធារណៈ និងទៀងទាត់តាមការកំណត់។

៣ សាលារៀនចាប់ផ្តើម សរសេររបាយការណ៍ដឹកនាំសាលារៀន ដោយប្រើសំនួរដឹកនាំទាំង៨ តាមការណែនាំក្នុងសៀវភៅ

122

| | | | | | |
|---|---|---|---|---|---|
| ១៤ | មានបរិស្ថានបៃតង អនាម័យ អគារសសិក្សា សង្ហារឹម និងបរិក្ខាសិក្សាបានថែរក្សា | គ្រោង | តាមផែនការឆ្នាំទី១ | តាមផែនការឆ្នាំទី២ | តាមផែនការឆ្នាំទី៣ |

សូចនាករទី១៤ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សកម្មភាព:

១ សិស្សនិងយុវជនមានតួនាទីសំខាន់ក្នុងកិច្ចការនេះ។ នាយកសាលារៀនមាននិងអនុវត្តផែនការរយៈពេល៣ឆ្នាំដាំដើមឈើតាមចំនួនដែលធ្វើទីធ្លាសាលារៀនគ្របដណ្តប់ដោយម្លប់ កិច្ចសហការណ៍ជាមួយក្រសួងពាក់ព័ន្ធធានានូវការមានកូនឈើមកដាំជាការសំខាន់ ជៀសវាងប្រើលុយសាលារៀនទិញកូនឈើ។ នាយកសាលារៀនពិភាក្សាជាមួយសិស្ស និងព្រមព្រៀងគ្នាថាសិស្សត្រូវដាំដើមឈើនៅផ្ទះរបស់ខ្លួនប៉ុន្មានដើម ធានាថាផ្ទះសិស្សមានម្លប់គ្រប់គ្រាន់។ នាយកសាលាត្រូវយកទីធ្លាសាលារៀនដាំដំណាំជាបន្លែគ្រប់ប្រភេទ ធ្វើឲ្យធ្លាសាលារៀន មានព័ណ៌បៃតង និងអាចយកផលិតផលធ្វើជាអាហារសម្រាប់សិស្សក្រីក្រហូបនៅសាលារៀន ជាជាងដាំផ្កាដែលពុំមានប្រយោជន៍ដល់ការហូបចុក។

២ សាលារៀនធានា មិនមានធុងសម្រាម និង មិនមានសម្រាម នៅក្នុងសាលារៀនឬថ្នាក់រៀនឡើយ។ នាយកសាលារៀនពិភាក្សាជាមួយសិស្សថា មិនត្រូវមានសម្រាមនៅផ្ទះ ឬក្នុងភូមិឡើយ។ សិស្សរួមថ្នាក់ណាដែលឃើញថាមានសម្រាមនៅផ្ទះនៃសិស្សនៅក្បែរខាង និងត្រូវមានការណែនាំគ្នា ឬមួយយកមកពិភាក្សានៅក្នុងថ្នាក់រៀនដោះស្រាយបញ្ហា។

៣ នាយកសាលាដាក់កិច្ចការឲ្យគ្រូបន្ទុកថ្នាក់ និងក្រុមប្រឹក្សាយុវជនតាមថ្នាក់ថែរក្សានូវ សួនបន្លែ អគារសិក្សា សង្ហារឹមតាមថ្នាក់ខ្លួន និងថែរក្សាសម្ភារៈបរិក្ខាវិទ្យាស្ត្រតាមកាលវិភាគសប្តាហ៍។



| | | | | | |
|---|---|---|---|---|---|
| ១៥ | មានកម្មវិធីបំណិនរកចំណូលតាមស្តង់ដា | គ្រោង | សម្រេចតាមផែនការឆ្នាំទី១ | សម្រេចតាមផែនការឆ្នាំទី២ | សម្រេចតាមផែនការឆ្នាំទី៣ |
| ១៦ | មានកម្មវិធីធានារ៉ាប់រងសង្គមនិងអភិវឌ្ឍសមត្ថភាព | | គ្រោង | សម្រេចតាមផែនការឆ្នាំទី១ | សម្រេចតាមផែនការឆ្នាំទី២ |

សូចនាករទី១៥ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សូចនាករទី១៦ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សកម្មភាព:

១ សកម្មភាពរៀបចំកម្មវិធីមាននៅក្នុងស្តង់ដាទី២រួចហើយ តែខ្លឹមសារនៅក្នុងនេះជាការធានានូវការអនុវត្តជាប់ជាប្រចាំនូវកម្មវិធីដែលបានគ្រោងទុក។ នាយកសាលាត្រូវទំនាក់ទំនងច្បាស់លាស់ជាមួយសាកលវិទ្យាល័យដៃគូ មន្ត្រីក្រសួងដែលមានតួនាទីជួយសាលារៀន និងមហាវិទ្យាល័យអប់រំក្នុងការអនុវត្តកម្មវិធីនេះ។៕ សាកលវិទ្យាល័យធានាផ្តល់ជំនួយបច្ចេកទេសពីការអនុវត្តបំណិន។ មន្ត្រីក្រសួងធានាផ្តល់ប្រឹក្សាពីការគ្រប់គ្រងកម្មវិធីធានាដល់ដំណើរការមាននិរន្តរភាព។ មហាវិទ្យាល័យអប់រំធានានូវការបង្រៀនចម្រុះមុខវិជ្ជា។

២ នៅឆ្នាំណាមួយក្រោយពីការអនុវត្តម្មវិធីបំណើនរកចំណូល នាយកសាលានិងគគសឬកបសពិភាក្សាគ្នាពីរបៀប*រៀបចំកម្មវិធីធានារ៉ាប់រងសង្គម និងអភិវឌ្ឍសមត្ថភាព* មន្ត្រី។ មន្ត្រីក្រសួងនិងទីប្រឹក្សាក្រសួងនឹងជួយសាលារៀនក្នុងការរៀបចំកម្មវិធីនេះ។ ការគ្រប់គ្រងនិងអនុវត្តកម្មវិធីនេះត្រូវមានដំណើរការតាមការណែនាំដែលមាននៅក្នុងសៀវភៅនេះ។

| | | | | | |
|---|---|---|---|---|---|
| | សរុបពិន្ទុស្តង់ដាទី៣ | ១៦ | ៣២ | ៤៨ | ៦៤ |
| | សរុបពីន្ទុជាក់ស្តែងនៅចុងឆ្នាំសិក្សាចំនួន (សរុបពិន្ទុពីកូឡោនខាងស្តាំទាំង៤) | ១៦ | | | |

ស្តង់ដាទី៤ ដំណើរប្រតិបត្តិការសាលារៀន

| | | | | | |
|---|---|---|---|---|---|
| ១ | ផែនការសមិទ្ធកម្មសូចនាករគន្លឹះរយៈពេលមធ្យមបានរៀបចំតាមការណែនាំ | រៀបចំឆ្នាំទី១ | រៀបចំឆ្នាំទី២ | រៀបចំឆ្នាំទី៣ | រៀបចំឆ្នាំទី៤ |
| ២ | ផលសម្រេចរយៈពេល៣ឆ្នាំ និងផែនការបង្រៀនរយៈពេល៣ឆ្នាំបានរៀបចំតាមការណែនាំ | រៀបចំឆ្នាំទី១ | រៀបចំឆ្នាំទី២ | រៀបចំឆ្នាំទី៣ | រៀបចំឆ្នាំទី៤ |
| ៣ | ផែនការកែលម្អសាលារៀនប្រចាំឆ្នាំបានរៀបចំតាមការណែនាំ | រៀបចំឆ្នាំទី១ | រៀបចំឆ្នាំទី២ | រៀបចំឆ្នាំទី៣ | រៀបចំឆ្នាំទី៤ |

សូចនាករទី១ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សូចនាករទី២ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សូចនាករទី៣ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សកម្មភាព:

១ ក្រោយការបញ្ចូលទិន្នន័យជាលទ្ធផលតេស្តស្តង់ដាដើមឆ្នាំសិក្សាចូលក្នុងតារាងហើយ នាយកសាលារៀនរៀបចំ ផែនការសមិទ្ធកម្មសូចនាករគន្លឹះរយៈពេលមធ្យម៦ឆ្នាំបន្ទាប់ផែនការផលសម្រេចរយៈពេល៣ឆ្នាំ និងផែនការបង្រៀនរយៈពេល៣ឆ្នាំ និងចុងក្រោយផែនការកែលម្អសាលារៀនប្រចាំឆ្នាំតាមលំដាប់លំដោយ។

២ ចំណាំ ចំពោះក្រុមគោលដៅ នៃសូចនាករណាមួយដែលមិនបានសម្រេច សាលារៀនត្រូវ ជំពាក់ក្រុមគោលដៅនោះ ហើយត្រូវ ផ្តោតការអនុវត្ត ធានាថា ចំនួនក្រុមគោលដៅដែលមិនបានសម្រេច ត្រូវយកទៅបូកបន្ថែមជាមួយ ក្រុមគោលដៅនៅឆ្នាំបន្ទាប់ ហើយអនុវត្តសូចនាករឬកិច្ចការនោះ ធានាសម្រេចឲ្យបាននៅឆ្នាំបន្ទាប់

៣ សូចនាករដែលមិនបានសម្រេច និងសកម្មភាពដោះស្រាយបញ្ហានៃសូចនាករនេះ ត្រូវមានកត់ត្រានៅក្នុងកំណត់ហេតុប្រជុំ ប្រចាំខែ ត្រីមាសនិងឆមាស និងចុងឆ្នាំ ។ ព័ត៌មានទាំងនេះត្រូវសរសេរបញ្ចូលទៅក្នុងរបាយការចុងឆ្នាំ ពិសេសរបាយការណ៍សំនួរដឹកនាំ

125

| | | | | | |
|---|---|---|---|---|---|
| ៤ | ការធ្វើតេស្តស្តង់ដាប្រចាំខែ និងត្រីមាសបានរៀបចំទៀងទាត់ | តេស្តខែ | បូកត្រីមាស | បូកត្រីមាស | បូកត្រីមាស |
| ៥ | លទ្ធផលតេស្តស្តង់ដាប្រចាំខែត្រូវបានយកប្រើប្រាស់ជួយដល់ការសិក្សារៀនសូត្ររបស់សិស្សរៀនយឺត | ទៀងទាត់ឆ្នាំទី១ | ទៀងទាត់ឆ្នាំទី២ | ទៀងទាត់ឆ្នាំទី៣ | ទៀងទាត់ឆ្នាំទី៤ |
| ៦ | លទ្ធផលតេស្តចុងត្រីមាសបានយកប្រើប្រាស់ក្នុងការរៀបចំផែនការបង្រៀន៣ខែតាមថ្នាក់រៀន | ទៀងទាត់ឆ្នាំទី១ | ទៀងទាត់ឆ្នាំទី២ | ទៀងទាត់ឆ្នាំទី៣ | ទៀងទាត់ឆ្នាំទី៤ |
| ៧ | ការប្រជុំប្រចាំខែ ត្រីមាស និងឆមាសបានប្រជុំតាមការណែនាំ | ប្រចាំខែ | បូកត្រីមាស | បូកឆមាស | បូកឆមាស |

សូចនាករទី៤ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សូចនាករទី៥ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សូចនាករទី៦ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សូចនាករទី៧ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សកម្មភាព:

១ នាយកសាលារៀនជាអ្នកទទួលខុសត្រូវក្នុងការអនុវត្តតស្តស្តង់ដាជាប់ជាប្រចាំ និងរក្សាគុណភាពឲ្យបានល្អ។ សំនួរតេស្តនឹងត្រូវបានផ្តល់ឲ្យដោយក្រសួងដើម្បីរក្សាកម្រិតគុណភាពស្តង់ដាតែមួយទូទាំងប្រទេស។

២ គ្រូត្រូវយកលទ្ធផលតេស្តចុងខែនិមួយៗមកប្រើប្រាស់ ដោយពិភាក្សាជាមួយសិស្ស និងជួយណែនាំសិស្សម្នាក់ឲ្យរៀនតាមសមត្ថភាពខ្វះចន្លោះរបស់សិស្សម្នាក់ៗ។

126

| | | | | | |
|---|---|---|---|---|---|
| ៤ | ការធ្វើតេស្តស្តង់ដាប្រចាំខែ និងត្រីមាសបានរៀបចំទៀងទាត់ | តេស្តខែ | បូកត្រីមាស | បូកត្រីមាស | បូកត្រីមាស |
| ៥ | លទ្ធផលតេស្តស្តង់ដាប្រចាំខែត្រូវបានយកប្រើប្រាស់ជួយដល់ការសិក្សារៀនសូត្ររបស់សិស្សរៀនយឺត | ទៀងទាត់ឆ្នាំទី១ | ទៀងទាត់ឆ្នាំទី២ | ទៀងទាត់ឆ្នាំទី៣ | ទៀងទាត់ឆ្នាំទី៤ |
| ៦ | លទ្ធផលតេស្តចុងត្រីមាសបានយកប្រើប្រាស់ក្នុងការរៀបចំផែនការបង្រៀន៣ខែតាមថ្នាក់រៀន | ទៀងទាត់ឆ្នាំទី១ | ទៀងទាត់ឆ្នាំទី២ | ទៀងទាត់ឆ្នាំទី៣ | ទៀងទាត់ឆ្នាំទី៤ |
| ៧ | ការប្រជុំប្រចាំខែ ត្រីមាស និងឆមាសបានប្រជុំតាមការណែនាំ | ប្រចាំខែ | បូកត្រីមាស | បូកឆមាស | បូកឆមាស |

៣ គ្រូទទួលបន្ទុកថ្នាក់ ជាមួយគ្រូមុខវិជ្ជាត្រូវប្រជុំពិនិត្យលទ្ធផលតេស្តស្តង់ដាប្រចាំត្រីមាស ដោយស្វែងរកនូវសំណុំមេរៀនតាមមុខវិជ្ជាដែលសិស្សភាគច្រើនរៀនមិនចេះ កំណត់មូលហេតុនិងឧបសគ្គរាំងស្ទាត់ការរៀនសូត្រ ដែលអាចមានដូច បណ្តាលមកពីការបង្រៀនមិនច្បាស់ ដោយសារសមត្ថភាពគ្រូឬមួយដោយការមិនទទួលខុសត្រូវរបស់គ្រូ មកពីការមិនសូវខិតខំរបស់សិស្សម្នាក់ៗ ដោយសារមូលហេតុសង្គមនិងសេដ្ឋកិច្ចរបស់សិស្សឬមួយដោយសារសមត្ថភាពបញ្ញាសិស្សទាបពេក(មកពីការអភិវឌ្ឍខួរក្បាលតាំងពីកុមារភាពមានការប៉ះទង្គិច) ហើយតើត្រូវជួយសិស្សម្នាក់ៗ តាមមេរៀននិមួយៗ។

៤ គ្រូទទួលបន្ទុកថ្នាក់ចងក្រងលទ្ធផលពីការប្រជុំ បញ្ជូនទៅនាយកសាលារៀន ហើយនាយកសាលារៀនសរុបព័ត៌មានពីគ្រូបន្ទុកថ្នាក់ទាំងអស់ជារបាយការណ៍សម្រាប់ការប្រជុំត្រីមាសជាមួយគគស ឬ កបស ដើម្បីដោះស្រាយ។

៥. នាយកសាលារៀនត្រូវផលិត របាយការណ៍ពីការរីកចម្រើនការអនុវត្តផែនការកែលម្អសាលារៀន និងរបាយការណ៍វិភាគពីការបង្រៀននិងសិក្សារៀនសូត្ររបស់សិស្ស។

127

| | | | | | |
|---|---|---|---|---|---|
| ៨ | ចំនួនដងអធិការកិច្ចផ្ទៃក្នុង និងការប្រជុំបច្ចេកទេសបានអនុវត្តតាមផែនការ | ៧-៧ | ៨-៨ | ៩-៩ | ១០-១០ |
| ៩ | ចំនួនគ្រូបង្រៀនបានចូលរៀនវគ្គអភិវឌ្ឍសមត្ថភាពជាប្រចាំ | គ្រោង | តាមគ្រោងឆ្នាំទី១ | តាមគ្រោងឆ្នាំទី២ | តាមគ្រោងឆ្នាំទី៣ |
| ១០ | ចំនួនគ្រូបង្រៀនបានចូលរួមអនុវត្តប្រព័ន្ធគ្រប់គ្រងការអនុវត្តការងាររបស់គ្រូបង្រៀន | >៨០% | >៨៥% | >៩០% | =>៩០% |
| ១១ | ចំនួននាយកសាលានិងនាយករងបានចូលរួមអនុវត្តប្រព័ន្ធគ្រប់គ្រងការអនុវត្តការងាររបស់នាយកសាលា | 0 | ១ | ២-៣ | ទាំងអស់ |

សូចនាករទី៨ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សូចនាករទី៩ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សូចនាករទី១០ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សូចនាករទី១១ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សកម្មភាព:

១ នាយកសាលារៀនពិភាក្សាជាមួយគ្រូបង្រៀនទាំងអស់ និងរៀបចំជាផែនការសម្រាប់គ្រូបង្រៀនចូលរួមរៀនសូត្រវគ្គលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន។

២ គ្រូបង្រៀនចូលរួមរៀនវគ្គលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន អនុវត្តកិច្ចការបានទទួលពីវគ្គ និងធានាសម្រេចបាននូវស្តង់ដាទី២។

៣ គ្រូបង្រៀនរៀបចំកិច្ចសន្យាលទ្ធផលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍសមត្ថភាព។ គ្រូបង្រៀនចូលរួមអនុវត្តការវាយតម្លៃពាក់កណ្តាលឆ្នាំនិងចុងឆ្នាំតាមការណែនាំ។ កបសមិនអនុញ្ញាតិឲ្យធ្វើបន្តទៀតឡើយ។

128

| | | | | | |
|---|---|---|---|---|---|
| ៨ | ចំនួនដងអធិការកិច្ចផ្ទៃក្នុង និងការប្រជុំបច្ចេកទេសបានអនុវត្តតាមផែនការ | ៧-៧ | ៨-៨ | ៩-៩ | ១០-១០ |
| ៩ | ចំនួនគ្រូបង្រៀនបានចូលរៀនវគ្គអភិវឌ្ឍសមត្ថភាពជាប្រចាំ | គ្រោង | តាមគ្រោងឆ្នាំទី១ | តាមគ្រោងឆ្នាំទី២ | តាមគ្រោងឆ្នាំទី៣ |
| ១០ | ចំនួនគ្រូបង្រៀនបានចូលរួមអនុវត្តប្រព័ន្ធគ្រប់គ្រងការអនុវត្តការងាររបស់គ្រូបង្រៀន | >៨០% | >៨៥% | >៩០% | =>៩០% |
| ១១ | ចំនួននាយកសាលានិងនាយករងបានចូលរួមអនុវត្តប្រព័ន្ធគ្រប់គ្រងការអនុវត្តការងាររបស់នាយកសាលា | 0 | ១ | ២-៣ | ទាំងអស់ |

៤ នាយកសាលារៀនអនុវត្តកិច្ចការអធិការកិច្ចផ្ទៃក្នុងទៅតាមការកំណត់ក្នុងកិច្ចសន្យាលទ្ធផលប្រចាំឆ្នាំរបស់គ្រូបង្រៀន។ ការធ្វើអធិការកិច្ចផ្ទៃក្នុងមានវត្ថុបំណងជួយគ្រូអនុវត្តការងាររបស់ខ្លួន មិនមែនមានបំណងស្វែងរកកំហុសរបស់គ្រូ និងបន្ទោសគ្រូបង្រៀននោះទេ។ ដូចគ្នានឹងការធ្វើអធិការកិច្ចពីថ្នាក់ក្រោមជាតិឬថ្នាក់ជាតិ ដែលមានបំណងជួយដល់ការកសាងសមត្ថភាពនិងលើកទឹកចិត្តគ្រូបង្រៀន ជាជាងការស្វែងរកកំហុសនិងស្តីបន្ទោស។ ប្រសិនបើមានអធិការណាម្នាក់ដែលអនុវត្តអធិការកិច្ចបែបស្វែងរកកំហុស នាយកសាលារៀនមានសិទ្ធិនិយាយជាមួយអធិការនោះថាការអនុវត្តកិច្ចការនេះខុសវត្ថុបំណងហើយ និងគប្បីកែប្រែ បើមិនដូច្នោះទេ នាយកសាលារៀននិងគគសឬកបសមិនអនុញ្ញាតិឲ្យធ្វើបន្តទៀតឡើយ។

129

| | | | | | |
|---|---|---|---|---|---|
| ១២ | ស្វ័យវាយតម្លៃសាលារៀននៅចុងឆ្នាំសិក្សាបានអនុវត្ត និងរបាយការណ៍ហិរញ្ញវត្ថុបានផលិតតាមការណែនាំ | អនុវត្តឆ្នាំទី១ | អនុវត្តឆ្នាំទី២ | អនុវត្តឆ្នាំទី៣ | អនុវត្តឆ្នាំទី៤ |

សូចនាករទី១២ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សកម្មភាព:

១ លទ្ធផលតេស្តស្តង់ដាចុងឆ្នាំត្រូវបូកសរុបចូលក្នុងតារាងកម្រិតសិស្សម្នាក់ៗ ថ្នាក់រៀននិមួយៗ និងសាលារៀនទាំងមូល។ នៅកម្រិតថ្នាក់រៀន គ្រូទទួលបន្ទុកថ្នាក់រៀបចំការប្រជុំកម្រិតថ្នាក់រៀន ពិនិត្យលទ្ធផលសិក្សារបស់សិស្ស និងពិភាក្សារកមូលហេតុដែលនៅសេសសល់ចុងឆ្នាំ។ ការពិនិត្យពិភាក្សាខ្លឹមសារគឺមានខ្លឹមសារ និងលំនាំដូចគ្នានឹងការប្រជុំប្រចាំត្រីមាសដែរ។ គ្រូទទួលបន្ទុកថ្នាក់បញ្ជូនរបាយការប្រជុំប្រចាំឆ្នាំមកនាយកសាលារៀន។ នាយករងទទួលបន្ទុកបច្ចេកទេសបូកសរុបលទ្ធផលរបាយការណ៍ពីគ្រូទទួលបន្ទុកថ្នាក់ទាំងអស់ចូលក្នុងរបាយការសរុបរបស់សាលារៀន និងជូនទៅនាយកសាលារៀន និងគគស ឬកបស។

២ នាយកសាលាដឹកនាំការប្រជុំស្វ័យវាយតម្លៃសាលារៀនចុងឆ្នាំ ដោយប្រើប្រាស់ របាយការណ៍ពីការរីកចម្រើនការអនុវត្តផែនការកែលម្អសាលារៀន និងរបាយការណ៍វិភាគពីការបង្រៀននិងសិក្សារៀនសូត្ររបស់សិស្ស។ ចុងបញ្ចប់នាយកសាលារៀនបូកសរុបផ្តល់ពិន្ទុដល់ស្តង់ដានិងសូចនាករនិមួយៗ និងសរុបពិន្ទុស្តង់ដាសហគមន៍សាលារៀនសម្រាប់ឆ្នាំ និងជូនទៅនាយកសាលារៀន និងគគស ឬកបស។

130

| ១៣ | ចំនួនដងប្រកួតប្រជែងអំណានភាសាខ្មែរ និងលំហាត់គណិតវិទ្យាជាមួយសាលាផ្សេងបានរៀបចំតាមការគ្រោង | គ្រោង | អនុវត្តឆ្នាំទី១ | អនុវត្តឆ្នាំទី២ | អនុវត្តឆ្នាំទី៣ |
|---|---|---|---|---|---|

សូចនាករទី១៣ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សកម្មភាពៈ

១ សកម្មភាពសម្រាប់សូចនាករនេះមានរៀបរាប់នៅខាងលើហើយ ដែលជាសកម្មភាពជាប់ជាបន្ត ហើយសកម្មភាពសម្រាប់សូចនាករនេះជាសកម្មភាពដែលត្រូវអនុវត្តនៅថ្ងៃទិវាអំណានជាតិ និងមានលក្ខណៈទ្រង់ទ្រាយធំ ដែលជាការប្រកួតកម្រិតរាជធានីឬខេត្ត ឬកម្រិតក្រសួង។ សិស្សដែលចូលរួមប្រកួតត្រូវតែជាសិស្សដែលបានជ្រើសរើសតាមការណែនាំពីក្រសួង ជៀសវាងជ្រើសរើសយកតែសិស្សពូកែមកប្រកួត។ ការជ្រើសរើសត្រូវអនុវត្តតាមរបៀបចាប់ឆ្នោតជ្រើសយកថ្នាក់ទី ឬ ទី៩ជាអទិភាព យកចំនួនសិស្សតាមការកំណត់របស់ក្រសួង ពោលគឺយ៉ាងច្រើន ៥នាក់ពីកម្រិតថ្នាក់មួយ និង ១០នាក់ពីសាលារៀនមួយ។ ការអនុវត្តបែបនេះតម្រូវឲ្យសាលារៀននិមួយៗត្រូវប្រឹងប្រែងជួយសិស្សជាប់ជាប្រចាំក្នុងការអាន ដើម្បីធានាថាល្បឿននៃអំណានគឺមានកម្រិតយ៉ាងតិចត្រឹមស្តង់ដាល្បឿនអំណាន ឬអាចអានលឿនជាងស្តង់ដា។



| ១៤ | ទិន្នន័យផ្ទៀងផ្ទាត់បានត្រូវបានផលិត ចងក្រង ប្រើប្រាស់ និងបិទផ្សាយសាធារណៈតាមការណែនាំ | ចងក្រងទិន្នន័យ | អនុវត្តឆ្នាំទី១ | អនុវត្តឆ្នាំទី២ | អនុវត្តឆ្នាំទី៣ |
|---|---|---|---|---|---|

សូចនាករទី១៤ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សកម្មភាពៈ

១ សាលារៀនត្រូវណែនាំសិស្សជួយគ្រប់គ្រងទិន្នន័យគ្រប់បែបយ៉ាងកម្រិតថ្នាក់រៀន និងកម្រិតសាលារៀន។

២ សាលារៀនត្រូវមានមន្ត្រីជាប់កិច្ចសន្យាម្នាក់សម្រាប់ជួយបញ្ចូលទិន្នន័យក្នុងប្រព័ន្ធទន់ បូកសរុបទិន្នន័យ និងបញ្ជូនទិន្នន័យមកក្រសួង។

៣ នាយកសាលារៀននឹងទទួលការបង្រៀនពីការគ្រប់គ្រងទិន្នន័យទាំងអស់ពីវគ្គបង្កើនគុណវុឌ្ឍិនាយកសាលារៀន។ នាយកសាលារៀននឹងត្រូវទទួលបាននូវការណែនាំពីការប្រើប្រាស់ទិន្នន័យ ព័ត៌មាន និងចំណេះដឹងជាពិសោធន៍សម្រាប់គ្រប់ប្រភេទអតិថិជន ដើម្បីជាប្រយោជន៍ដល់ការអភិវឌ្ឍសាលារៀននិងសហគមន៍។

| | | | | | |
|---|---|---|---|---|---|
| ១៥ | កម្មវិធីអប់រំមាតាបិតា និងគ្រូបង្រៀនទប់អំពើហិង្សានៅផ្ទះនិងសាលារៀនបានរៀបចំតាមការណែនាំ | ប្រមូលទិន្នន័យ | អនុវត្តឆ្នាំទី១ | អនុវត្តឆ្នាំទី២ | អនុវត្តឆ្នាំទី៣ |
| ១៦ | ការពិនិត្យស្វែងរកសិស្សខ្សោយគំហើញ និងស្តាប់បានអនុវត្តទៀងទាត់រាល់ដើមឆ្នាំសិក្សា | គ្រោង | អនុវត្តឆ្នាំទី១ | អនុវត្តឆ្នាំទី២ | អនុវត្តឆ្នាំទី៣ |

សូចនាករទី១៥ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សូចនាករទី១៦ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សកម្មភាព:

១ នាយកសាលារៀនរៀបចំការប្រជុំ ជាការបង្រៀននិងរៀនសូត្រ ពីការអប់រំមាតាបិតាសិស្សពី សមត្ថភាពចិត្តនិងសង្គម និងរបៀបថែទាំកូន។ ខ្លឹមសារនិងរបៀបប្រជុំអប់រំពីការថែទាំកូនមាននៅក្នុងសៀវភៅនេះ ហើយនាយកសាលាត្រូវអនុវត្តតាមការណែនាំនេះ។ បរិស្ថានដែលសិស្សរស់នៅ ទាំងនៅផ្ទះ និងនៅសាលារៀនត្រូវតែមានសភាពដូចគ្នា នោះទើបអាចជួយសិស្សឲ្យបណ្តុះបាននូវសមត្ថភាពចិត្តនិងសង្គមដែលគេត្រូវការ។

២ នាយកសាលានិងគ្រូបង្រៀនអនុវត្តតាមការណែនាំរបស់ក្រសួងពីការស្វែងរកសិស្សដែលអាចមានភាពខ្សោយគំហើញចំនួន XX និងខ្សោយស្តាប់ចំនួន XX។ ព្រោះថាបើសិស្សមានបញ្ហាណាមួយនៃបញ្ហាទាំងពីរនេះ សិស្សមិនអាចរៀនបានឡើយ។ ក្រោយពីការរកឃើញហើយ គ្រូបង្រៀនត្រូវអញ្ជើញមាតាបិតាសិស្សមកពិភាក្សា ដើម្បីមាតាបិតានាំសិស្សទៅវាស់ផ្នែកនិងទិញវ៉ែនតាពាក់ ឬមួយទៅ ពេទ្យភ្នែកឬសាលាគថ្លង់ ដើម្បីវាស់កម្រិតទំងន់នៃការខ្សោយស្តាប់ និងទិញប្រដាប់ជំនួនស្តាប់សម្រាប់សិស្ស។ ប្រសិនបើសិស្សជាកូនអ្នកក្រ សាលារៀនត្រូវជួយផ្នែកហិរញ្ញវត្ថុដល់សិស្ស ដែលជាការចំណាយពីថវិការរដ្ឋផ្តល់ឲ្យសាលារៀន។

៣ នាយកសាលារៀនត្រូវចាត់តំណាងសិស្សចងក្រងព័ត៌មានទាំងនេះ ដើម្បីបញ្ចូលក្នុងរបាយការណ៍ និងប្រើប្រាស់ជាព័ត៌មានផ្សព្វផ្សាយដល់សាធារណៈពីសកម្មភាពសង្គមដែលសាលារៀនបានអនុវត្តដើម្បីជាផ្នែកនៃការថែរក្សាគ្នានៅក្នុងសហគមន៍។



| | | | | | |
|---|---|---|---|---|---|
| ១៥ | កម្មវិធីអប់រំមាតាបិតា និងគ្រូបង្រៀនទប់អំពើហិង្សានៅផ្ទះនិងសាលារៀនបានរៀបចំតាមការណែនាំ | ប្រមូលទិន្នន័យ | អនុវត្តឆ្នាំទី១ | អនុវត្តឆ្នាំទី២ | អនុវត្តឆ្នាំទី៣ |
| ១៦ | ការពិនិត្យស្វែងរកសិស្សខ្សោយគំហើញ និងស្តាប់បានអនុវត្តទៀងទាត់រាល់ដើមឆ្នាំសិក្សា | គ្រោង | អនុវត្តឆ្នាំទី១ | អនុវត្តឆ្នាំទី២ | អនុវត្តឆ្នាំទី៣ |

៤. អប់រំសិស្សនិងមាតាបិតាពី ច្បាប់ចរាចរណ៍ ផ្តោតលើចរិយាគ្រោះថ្នាក់ពេលបើកបរ និងចរិយាផ្តោតសំខាន់ៗដែលត្រូវប្រតិបត្តិពេលបើកបរ និងសម្រេចចិត្តជាមួយមាតាបិតានិសិស្សថានឹងគោរពដោយហ្មត់ចត់នូវច្បាប់ចរាចរណ៍ និងចរិយាដែលត្រូវប្រតិបត្តិ ជាមួយការសន្យាថាសហគមន៍នឹងចម្រេចបាននូវសុវត្ថិភាពចរាចរណ៍ក្នុងសហគមន៍។

៥ សាលារៀនត្រូវផ្តល់ទិន្នន័យពីកុមារ សិស្ស សាលា ថ្នាក់រៀន និងគ្រូបង្រៀននៅតំបន់គោះមកក្រសួងនៅខែធ្នូ ២០២២។

| | | | | | |
|---|---|---|---|---|---|
| | ពិន្ទុសរុបស្តង់ដាទី៤ | ១៦ | ៣២ | ៤៨ | ៦៤ |
| | សរុបពិន្ទុជាក់ស្តែងនៅចុងឆ្នាំសិក្សាចំនួន (សរុបពិន្ទុពីកូឡោនខាងស្តាំទាំង៤) | ១៦ | | | |

| | | | | | |
|---|---|---|---|---|---|
| ស្តង់ដាទី៥ គណនេយ្យភាពថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ | | | | | |
| ១ | ចំនួនដងនាយកសាលានិងនាយកសាលារងបានទទួលការហ្វឹកហាត់អនុវត្តការគ្រប់គ្រងតាមសាលារៀន | ១-២ | ៣-៤ | ៥-៦ | ៧-៨ |
| ២ | ចំនួនដងគ្រូបង្រៀនបានទទួលការហ្វឹកហាត់ការបង្រៀនចម្រុះមុខវិជ្ជាតាមផែនការ | គ្រោង | តាមគ្រោងឆ្នាំទី១ | តាមគ្រោងឆ្នាំទី២ | តាមគ្រោងឆ្នាំទី៣ |

សូចនាករទី១ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សូចនាករទី២ ពិន្ទុដើមឆ្នាំ (ជាពិន្ទុចុងឆ្នាំមុន) XX និងពិន្ទុគ្រោងចុងឆ្នាំនេះ XX។ សកម្មភាព:

| ៨. ចំនួនដងអធិការកិច្ចផ្ទៃក្នុង និងការប្រជុំបច្ចេកទេសបានអនុវត្តតាមផែនការ | | | | |
| ៩. ចំនួនគ្រូបង្រៀនបានចូលរៀនវគ្គអភិវឌ្ឍសមត្ថភាពជាប្រចាំ | | | | |
| ១០. ចំនួនគ្រូបង្រៀនបានចូលរួមអនុវត្តប្រព័ន្ធគ្រប់គ្រងការអនុវត្តការងាររបស់គ្រូបង្រៀន | | | | |
| ១១. ចំនួននាយកសាលានិងនាយករងបានចូលរួមអនុវត្តប្រព័ន្ធគ្រប់គ្រងការអនុវត្តការងាររបស់នាយកសាលា | | | | |
| ១២. ស្វ័យវាយតម្លៃសាលារៀននៅចុងឆ្នាំសិក្សាបានអនុវត្ត និងរបាយការណ៍ហិរញ្ញវត្ថុបានផលិតតាមការណែនាំ | | | | |
| ១៣. ចំនួនដងប្រកួតប្រជែងអំណានភាសាខ្មែរ និងលំហាត់គណិតវិទ្យាជាមួយសាលាផ្សេងបានរៀបចំតាមការគ្រោង | | | | |
| ១៤. ទិន្នន័យជឿជាក់បានត្រូវបានផលិត ចងក្រង ប្រើប្រាស់ និងបិទផ្សាយសាធារណៈតាមការណែនាំ | | | | |
| ១៥. កម្មវិធីអប់រំមាតាបិតា និងគ្រូបង្រៀនទប់អំពើហិង្សានៅផ្ទះនិងសាលារៀនបានរៀបចំតាមការណែនាំ | | | | |
| ១៦. ការពិនិត្យស្វែងរកសិស្សខ្សោយគំហើញ និងស្តាប់បានអនុវត្តទៀងទាត់រាល់ដើម<br>ឆ្នាំសិក្សា | | | | |
| **ស្តង់ដាទី៥ គណនេយ្យភាពថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ** | | | | |
| ១. ចំនួនដងនាយកសាលានិងនាយកសាលារងបានទទួលការហ្វឹកហាត់អនុវត្តការគ្រប់គ្រងតាមសាលារៀន | | | | |
| ២. ចំនួនដងគ្រូបង្រៀនបានទទួលការហ្វឹកហាត់ការបង្រៀនចម្រុះមុខវិជ្ជាតាមផែនការ | | | | |

| | | | | |
|---|---|---|---|---|
| ៣. ចំនួនដងទស្សនៈកិច្ចផ្តល់ការគាំទ្រពីក្រុមការងារតំបន់បានអនុវត្តតាមផែនការ | | | | |
| ៤. ចំនួនដងទស្សនៈកិច្ចផ្តល់ការគាំទ្រពីមន្ទីរអប់រំបានអនុវត្តតាមផែនការ | | | | |
| ៥. ចំនួនដងទស្សនៈកិច្ចផ្តល់ការគាំទ្រពីការិយាល័យអប់រំបានអនុវត្តតាមផែនការ | | | | |
| ៦. ការបង្រៀនបំណិនកសិកម្ម និងបច្ចេកទេសបានអនុវត្តតាមផែនការ | | | | |
| ៧. ចំនួនគ្រូបង្រៀនខ្វះតាមមុខវិជ្ជាថយចុះតាមផែនការ | | | | |
| ៨. ចំនួននាយកសាលានិងនាយកសាលារងមានជាផ្លូវតាមបទដ្ឋាន | | | | |
| ៩. កាតរបាយការណ៍សាលារៀនបានផលិត និងបិទផ្សាយ | | | | |
| | | | | |

*សម្គាល់*

*នាយកសាលាទទួលខុសត្រូវក្នុងការរៀបចំរបាយការណ៍នេះ ដោយមានការជួយពីនាយករងសាលារៀនទទួលបន្ទុកបច្ចេកទេស សម្រាប់បូកសរុបរបាយការណ៍ពីគ្រូបន្ទុកថ្នាក់ និងនាយករងសាលារៀនទទួលបន្ទុករដ្ឋបាលសាលារៀន ក្នុងការរៀបចំរបាយការណ៍ពីការរីកចម្រើនការអនុវត្តផែនការកែលម្អសាលារៀន។ ចំពោះសូចនាករមិនបានសម្រេច និងសកម្មភាពមិនបានអនុវត្ត ត្រូវដាក់ពណ៌ក្រហម និងធ្វើជាអក្សរផ្តេក។*

*ក្រោយពីការបញ្ចប់សរសេររបាយការណ៍រីកចម្រើនខាងលើហើយ នាយកសាលា នាយករងសាលារៀន គ្រូបង្រៀន និងក្រុមប្រឹក្សាកុមារយុវជនត្រូវពិភាក្សាកំណត់ពិន្ទុ តាមគ្រប់ស្តង់ដា និងសូចនាកសម្រាប់ចុងចប់នៃឆ្នាំទី១ និងកំណត់ពិន្ទុស្តង់ដា និងសូចនាកសម្រាប់ផែនការឆ្នាំបន្ទាប់ ដូចមានក្នុងតារាងខាងក្រោម*

# ផែនការកែលម្អសាលារៀន និងថវិកា

ឈ្មោះសាលារៀន.......................................... លេខកូដ............................
ឈ្មោះនាយកសាលា...................................... លេខទូរស័ព្ទ.......................
ភូមិ.......................................................... ឃុំ/សង្កាត់..........................
ក្រុង/ស្រុក/ខណ្ឌ........................................... រាជធានី/ខេត្ត.......................

| ពិន្ទុអប្បបរិមា | ស្តង់ដាទី១ ៣៩ | | ស្តង់ដាទី២ ៤៨ | | ស្តង់ដាទី៣ ៤៨ | | ស្តង់ដាទី៤ ៤៨ | | ស្តង់ដាទី៥ ២៧ | | សរុបពិន្ទុ ២១០ | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ដើមឆ្នាំ | ចុងឆ្នាំ | ដើមឆ្នាំ | ចុងឆ្នាំ | ដើមឆ្នាំ | ចុងឆ្នាំ | ដើមឆ្នាំ | ចុងឆ្នាំ | ដើមឆ្នាំ | ចុងឆ្នាំ | ដើមឆ្នាំ | ចុងឆ្នាំ |
| ពិន្ទុឆ្នាំ ២០២៣ | ០ | ១៣ | ០ | ១៤ | ០ | ១៦ | ០ | ១៦ | ០ | ៩ | ០ | ៧០ |
| ពិន្ទុឆ្នាំ ២០២៤ | | | | | | | | | | | | |
| ពិន្ទុឆ្នាំ ២០២៥ | | | | | | | | | | | | |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ពិន្ទុឆ្នាំ ២០២៦ | | | | | | | | | | | | |
| ពិន្ទុឆ្នាំ ២០២៧ | | | | | | | | | | | | |
| ពិន្ទុឆ្នាំ ២០២៨ | | | | | | | | | | | | |

# ផែនការសកម្មភាព
# និងកាលវិភាគអនុវត្តឆ្នាំរបស់សាលារៀន

ឈ្មោះសាលា៖ ................................ ឈ្មោះនាយក៖ ................................

ឈ្មោះស្រុក៖ ................................ ឈ្មោះខេត្ត៖ ................................

| សកម្មភាព | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| **ស្តង់ដាទី១៖ សាលារៀនដំណើរការសម្រាប់ផលសម្រេចការអប់រំនិងការសិក្សារបស់សិស្ស (ទិន្នន័យយេនឌ័រនៅគ្រប់សូចនាករ)** | | | | | | | | | | | | |
| សូចនាក ១ | | | | | | | | | | | | |
| *១. សហការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រធានភូមិ ក្នុងការពិនិត្យបញ្ជីឈ្មោះកុមារ ៧២ខែ ដល់អាយុត្រូវចូលរៀននៅបឋមសិក្សា និងសិស្សបឋមសិក្សាជាក់ស្តែងម្តងម្នាក់ៗ ដែលកំពុងរៀនថ្នាក់ទី១ ដល់ទី៦។ ផ្តល់ព័ត៌មានដល់មាតាបិតាឱ្យចុះឈ្មោះចូលរៀនថ្នាក់ទី១។ មាតាបិតាចុះឈ្មោះកូនចូលរៀននៅថ្នាក់ទី១រហូតដល់ថ្នាក់ទី៦ (យកតែសិស្សជាក់ស្តែង) ចុះឈ្មោះនៅសាលាបឋមសិក្សា យ៉ាងយូរត្រឹមថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២២។ ចំពោះគ្រួសារចំណាកស្រុកមករស់នៅទីតាំងថ្មី សាលារៀនកត់ត្រាទិន្នន័យកុមារ ឬសិស្សទាំងអស់ (គ្រប់គ្រួសារចំណាកស្រុកដែលមករស់នៅក្នុងភូមិឃុំយើង) និងជម្រាបមាតាបិតាឱ្យនាំកូនមកចុះឈ្មោះចូលរៀន សាលាមិនទារឯកសារ ឬសំបុត្រកំណើតទេ ព្រោះថាគាត់មិនមាន ម្យ៉ាងវិញទៀតសាលាដាច់ខាតមិនទារលុយពីមាតាបិតាសិស្សឡើយ។* | | | | | | | | | | | | |
| *២. នៅអាទិត្យបន្ទាប់ពីថ្ងៃចុះឈ្មោះចូលរៀន ប្រសិនមិនឃើញសិស្សណាម្នាក់មកចុះឈ្មោះទេ សាលារៀននឹងចាត់តំណាងចុះដល់ផ្ទះសិស្ស ពិភាក្សាជាមួយមាតាបិតាឬអ្នកអាណាព្យាបាល ផ្តល់សម្ភារៈសិក្សាដល់សិស្ស ចុះឈ្មោះក្នុងបញ្ជីចុះឈ្មោះចូលរៀននៅផ្ទះសិស្សតែម្តង និងផ្តាំផ្ញើឱ្យគេទៅរៀននៅថ្ងៃបន្ទាប់។* | | | | | | | | | | | | |
| *៣. អនុវត្តការធ្វើតេស្តស្តង់ដាវិនិច្ឆ័យសមត្ថភាពសិស្ស បញ្ចូលលទ្ធផលក្នុងតារាង និងបិទផ្សាយលទ្ធផលតេស្តជាសាធារណៈ។* | | | | | | | | | | | | |
| *៤. គណៈកម្មការគ្រប់គ្រងសាលារៀនអនុម័ត ឱ្យសាលារៀនបញ្ចូលទិន្នន័យជាលទ្ធផលពីការធ្វើតេស្តស្តង់ដា ចូលក្នុងតារាងសរុបលទ្ធផលតេស្តវិនិច្ឆ័យដើមឆ្នាំថ្នាក់ទី១ចុងឆ្នាំ និងពីថ្នាក់ទី២ រហូតដល់ទី៦ (សម្រាប់មធ្យមសិក្សាគឺ ថ្នាក់ទី៦ឡើងទី៧ និងពីថ្នាក់ទី៧ រហូតដល់ទី១២)។* | | | | | | | | | | | | |
| សូចនាក ២ | | | | | | | | | | | | |
| *១. នៅពេលមានសិស្សណាអវត្តមាន សាលារៀននឹងចាត់មនុស្សចុះដល់ផ្ទះសិស្ស ពិភាក្សា ជាមួយមាតាបិតា ឬអ្នកអាណាព្យាបាលដោះស្រាយបញ្ហាកំពុងមាន និងផ្តាំផ្ញើឱ្យសិស្សទៅរៀននៅថ្ងៃបន្ទាប់។ ជៀសវាងដាច់ខាតនូវការបន្តអវត្តមាន មិនឱ្យលើសពី៤ដងក្នុងមួយឆ្នាំ។ សាលារៀនមិនអនុញ្ញាតឱ្យសិស្សណាអវត្តមាន ក្រៅពីមានមូលហេតុឈឺពិតប្រាកដនោះទេ។* | | | | | | | | | | | | |
| សូចនាក ៣ | | | | | | | | | | | | |
| *១. សាលារៀននឹងឱ្យសិស្សទាំងអស់ឡើងថ្នាក់ និងពុំទុកឱ្យសិស្សណាម្នាក់ត្រួតថ្នាក់ទេ។ តែសាលារៀននិងគ្រូបង្រៀន ត្រូវធ្វើផែនការសាលារៀន និងផែនការថ្នាក់រៀន ជួយសិស្ស* | | | | | | | | | | | | |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| *ឱ្យរៀនទាន់កម្រិតថ្នាក់ ដែលសិស្សកំពុងរៀន និងទាន់កម្មវិធីសិក្សានៃថ្នាក់កំពុងរៀន។ គ្រូបង្រៀនត្រូវសហការគ្នាតាមជួយសិស្សរហូត៣ឆ្នាំ និងរហូត៦ឆ្នាំ តាមភាពជាក់ស្តែងនៃសិស្សម្នាក់ៗ ពោលគឺពីថ្នាក់ទី៧ ដល់ថ្នាក់ទី១២ ធានាថាគេអាចរៀនបានដល់កម្រិតយ៉ាងហោចនិទ្ទេសល្អ (B)។*<br><br>*សាលារៀន និងគ្រូបង្រៀនប្តេជ្ញាចិត្តជួយសិស្សតាមវិធីដូចនេះ៖*<br>*ក. ជួយរៀនបន្ថែមអានអក្សរពីកម្រិតសមត្ថភាពរបស់គេ ដែលបង្ហាញដោយតេស្តវិនិច្ឆ័យ ជាមួយការអានតាមប្រព័ន្ធអានអក្សរឥន្ទធនូ អានឃ្លា អានល្បឿន ប្រកួតប្រជែងអាន...។*<br>*ខ. ប្រាប់អត្ថបទឱ្យសិស្សអាននៅផ្ទះ ឬនៅក្រៅថ្នាក់រៀន។*<br>*គ. ដាក់លំហាត់ឱ្យសិស្សធ្វើនៅផ្ទះ គ្រូកែលំហាត់ និងជួយសិស្សរៀនបំពេញបន្ថែម។*<br>*ឃ. គ្រូមិនយកលុយពីសិស្សក្រីក្រទេ តែសាលារៀនជួយពិភាក្សាជាមួយមាតាបិតាក្នុងថ្នាក់ ដើម្បីស្វែងរកការជួយឧបត្ថម្ភពីគ្រួសារមានលទ្ធភាព។*<br>*ង. សាលារៀនមានមូលនិធិ ជាចំណូលពីកម្មវិធីបំណិន អាចយកមកជួយគ្រូបង្រៀនបាន។* | | | | | | | | | | | | |
| សូចនាក ៤-៩ | | | | | | | | | | | | |
| *១. នៅពេលប្រជុំដើមឆ្នាំសិក្សា ក្រោយពីការរៀបចំផែនការកែលម្អប្រចាំឆ្នាំហើយ នាយកសាលានិងគគសឬកបស កោះអញ្ជើញសហគមន៍ទាំងអស់មកប្រជុំដើមឆ្នាំសិក្សា។ គគសឬនាយកសាលាប្រកាសពីបេសកកម្ម គោលបំណង និងផែនការកែលម្អសាលារៀន និងសំណើសិស្ស មាតាបិតាសិស្ស សហគមន៍ទាំងអស់ចូលរួមសហការពេញទំហឹងជាមួយសាលារៀននិងគ្រូបង្រៀន ជួយសិស្សរៀនមានសមត្ថភាពមុខវិជ្ជា រៀនបំណិនរកចំណូលនិងរកចំណូលបាន ព្រមទាំងសាលារៀនជួយសិស្សឱ្យក្លាយជាមនុស្សល្អក្នុងសហគមន៍។ សាលារៀនត្រូវយកពង្រាងផែនការ ទៅពិគ្រោះយោបល់ជាមួយប្រជាជននៅតាមភូមិ កែលម្អផែនការ តាមមតិយោបល់ប្រជាជន និងបិទផ្សាយផែនការជាសាធារណៈ។* | | | | | | | | | | | | |
| សូចនាក ១០-១១ | | | | | | | | | | | | |
| *១. រៀបចំការប្រកួតប្រជែងល្បឿនអំណាន និងគណិតវិទ្យាសម្រាប់សាលារៀនខ្លួនឯង ឬជាមួយសាលារៀនក្នុងក្រុង ស្រុក ខណ្ឌ ឬរាជធានី ខេត្ត ឬជាមួយសាលារៀនឯកជន។ បញ្ចូលថ្ងៃខែឆ្នាំនៃការព្រមព្រៀងប្រកួតប្រជែង ជាមួយសាលារៀនផ្សេងៗ។ ការប្រកួតប្រជែងនេះ ត្រូវអនុវត្តជាប់ជាប្រចាំខែ និងត្រីមាស វាស់វែងការរីកចម្រើន និងភាពជោគជ័យនៃការសិក្សា។* | | | | | | | | | | | | |
| សូចនាក ១២-១៣ | | | | | | | | | | | | |
| *១. ប្រើសំណួរតេស្តដែលក្រសួងផ្តល់សំណួរតេស្តស្តង់ដាពីក្រសួង (កម្រិតងាយ មធ្យម លំបាក និងកម្រិតតេសអន្តរជាតិ) ហើយរដ្ឋបាលនៃការប្រឡងត្រូវមាន ភាពគ្រប់ជ្រុងជ្រោយតាមការណែនាំ។* | | | | | | | | | | | | |
| *២. លទ្ធផលប្រឡងនឹងត្រូវបញ្ជូនទៅក្រសួងសម្រាប់ធ្វើការវិភាគ ផលិតរបាយការណ៍ និងត្រូវមានព័ត៌មានត្រឡប់មកសាលារៀនវិញ នៅពេលរៀបចំសិក្ខាសាលារៀងរាល់ឆ្នាំ។* | | | | | | | | | | | | |
| **ស្តង់ដាទី២៖ ថ្នាក់រៀនដំណើរការសម្រាប់ការបង្រៀន និងរៀននៃសិស្សម្នាក់ៗ** | | | | | | | | | | | | |
| សូចនាក ១-២ | | | | | | | | | | | | |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| *១. គ្រូទទួលបន្ទុកថ្នាក់ ប្រជុំនៅចុងខែធ្នូនៃឆ្នាំ មុនចាប់ចូលបវេសនកាល ជាមួយគ្រូមុខវិជ្ជាទាំងអស់ និងសិស្សទាំងអស់នៃថ្នាក់។ យកក្រុមគោលដៅឆ្នាំបច្ចុប្បន្ន(២០២២) នៃផែនការសិក្សា៣ឆ្នាំជាគោល សម្រាប់ធ្វើផែនការបង្រៀន៣ឆ្នាំ តាមមុខវិជ្ជា រួចបន្តរៀបចំផែនការបង្រៀនប្រចាំឆ្នាំតាមមុខវិជ្ជា។* | | | | | | | | | | | | |
| *២. សិស្សម្នាក់ៗត្រូវរៀបចំផែនការរៀនសូត្ររបស់ខ្លួន ដោយមានការជួយពីសិស្សរួមថ្នាក់បើត្រូវការ។ ផែនការរៀនសូត្ររបស់សិស្ស ត្រូវមានកម្រិតផលសម្រេចពីការរៀនសូត្រ ដែលសរុបសិស្សទាំងអស់មានចំនួនស្មើគ្នានឹងផែនការបង្រៀនប្រចាំឆ្នាំតាមមុខវិជ្ជារបស់ថ្នាក់រៀន។* | | | | | | | | | | | | |
| សូចនាក ៣-៥ | | | | | | | | | | | | |
| *១. បន្ទាប់ពីការប្រជុំខាងលើ គ្រូទទួលបន្ទុកថ្នាក់ប្រជុំជាមួយគ្រូមុខវិជ្ជា រៀបចំបំណែងចែកកម្មករវិធីសិក្សាបង្រៀនប្រចាំសប្តាហ៍ និងកាលវិភាគបង្រៀនលម្អិតតាមមេរៀន ប្លង់មេរៀនតាមគ្រប់មេរៀន ផែនការបង្រៀន៣ខែ។ គ្រូទទួលបន្ទុកថ្នាក់ត្រូវបញ្ជូនផែនការទាំងអស់នេះទៅនាយកសាលារៀន។* | | | | | | | | | | | | |
| *២. នាយកសាលាពិនិត្យផ្ទៀងផ្ទាត់ថាគ្រប់ថ្នាក់រៀន និងគ្រប់កម្រិតថ្នាក់មានប្រភេទផែនការទាំងអស់ខាងលើ។* | | | | | | | | | | | | |
| សូចនាក ៦-៧ | | | | | | | | | | | | |
| *១. គ្រូទទួលបន្ទុកថ្នាក់សម្របសម្រួល ក្នុងការបញ្ចូលទិន្នន័យពីការធ្វើតេស្តស្តង់ដាប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំចូលក្នុងតារាង ដោយមានការជួយពីសិស្សនិងគ្រូបង្រៀន។* | | | | | | | | | | | | |
| *២. គ្រូទទួលបន្ទុកថ្នាក់ត្រូវដឹកនាំការប្រជុំទៀងទាត់ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ។ ប្រើលទ្ធផលពីតេស្តស្តង់ដា ពិភាក្សាជាមួយគ្រូបង្រៀន  ព្រមជាមួយការព្រមព្រៀងជាមួយគ្រូបង្រៀនរៀបចំផែនការបង្រៀន៣ខែបន្ទាប់។* | | | | | | | | | | | | |
| *៣. សិស្សម្នាក់ៗបញ្ចូលទិន្នន័យតេស្តចូលក្នុង តារាងតាមដានការសិក្សារបស់ខ្លួន និងត្រូវប្រឹងប្រែងរៀនសូត្រតាមការណែនាំរបស់គ្រូនូវមុខវិជ្ជាណា ដែលនៅរៀនយឺត។* | | | | | | | | | | | | |
| *៤. សិស្សម្នាក់ៗអានអត្ថបទឬមេរៀនគ្រូប្រាប់ រួចឆ្លើយនឹងសំណួរ ឬមួយឆ្លើយនឹងសំណួរជ្រើសរើស ឬមួយដោះស្រាយចំណោទ។ សិស្សអាចសិក្សាគ្រប់ពេល និងនៅគ្រប់ទីកន្លែង។ សិស្សនឹងអាចប្រើបច្ចេកវិទ្យា ក្នុងការរៀនសូត្រដោយខ្លួនឯងនេះ។* | | | | | | | | | | | | |
| *៥. គ្រូបង្រៀនត្រូវអនុវត្តតេស្តស្តង់ដានៅគ្រប់មេរៀនដែលបង្រៀន ធានាថាសិស្សទាំងអស់រៀនចេះ។ សាលារៀនអនុវត្តតេស្តស្តង់ដាប្រចាំខែ សរុបលទ្ធផលតេស្ត វិភាគលទ្ធផលតេស្តនៅចុងខែរៀងរាល់ខែ ដោយធៀបជាមួយផែនការបង្រៀន៣ខែ និងឈានទៅធានាថាក្រុមគោលដៅចុងឆមាសទី១ និងចុងឆ្នាំនឹងត្រូវបានសម្រេច។* | | | | | | | | | | | | |
| *៦. គ្រូបង្រៀនត្រូវរៀបចំការប្រជុំជាមួយមាតាបិតាសិស្សនិងសិស្ស ពន្យល់ពីខ្លឹមសារមេរៀនណាខ្លះ ដែលសិស្សនៅរៀនយឺត ពិភាក្សាកំណត់សកម្មភាពត្រូវអនុវត្ត ដើម្បីដោះស្រាយនូវខ្លឹមសារមេរៀនដែលសិស្សរៀនយឺត។ គ្រូបង្រៀនត្រូវបង្រៀនខ្លឹមសារមេរៀននោះឡើងវិញ ប្រសិនសិស្សភាគច្រើនមិនចេះ មាតាបិតាត្រូវជួយកូនឱ្យរៀននៅផ្ទះតាមការ* | | | | | | | | | | | | |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ណែនាំរបស់គ្រូ ឬមួយរៀននៅសាលាពេលល្ងាចនិងយប់បន្ថែម ហើយសិស្សត្រូវអានអក្សរឱ្យឮៗរហូត ទោះនៅកន្លែងណាក៏ដោយ និងធ្វើលំហាត់តាមការណែនាំពីគ្រូ។ | | | | | | | | | | | | |
| ៧. ពិសេសសម្រាប់សិស្សដែលមាននិទ្ទេស D E F គ្រូបង្រៀនត្រូវពន្យល់មាតាបិតាថា កូនរបស់គាត់មានគម្លាតសមត្ថភាពតាំងពី៣ឬ៤ឆ្នាំមុន ដូចនេះគាត់ត្រូវរៀនបំពេញគម្លាតសមត្ថភាពទាំងនេះសិន មុននឹងគាត់អាចរៀនកម្មវិធីសិក្សានៃថ្នាក់កំពុងរៀន។ ដូចនេះសិស្សត្រូវរៀនបន្ថែមម៉ោងពេលយប់តាំងពីម៉ោង៦ រហូតដល់ម៉ោង១០យប់ ដើម្បីឱ្យការសិក្សាសរុបបានពី១២ទៅ១៥ម៉ោងក្នុងមួយថ្ងៃទើបអាចរៀនទាន់។ ដើម្បីធ្វើការបង្រៀនបន្ថែមម៉ោងច្រើនដូចនេះបាន លុះណាមាតាបិតាសិស្សអាចជួយបង់ថ្លៃសិក្សាជាការស្ម័គ្រចិត្ត ដើម្បីគ្រូបង្រៀនអាចរៀបចំថ្នាក់ឱ្យសិស្សរៀនបាន។ ការបង់ថ្លៃមិនកំណត់ចំនួនទេ គ្រួសារអ្នកធូរធារអាចបង់ច្រើនតាមលទ្ធភាព តែគ្រួសារក្រីក្រអាចមិនបាច់បង ឬបង់តិចតួចតាមការដែលចង់រួមចំណែក។ ការបង់ថ្លៃត្រូវបង់ទៅនាយកសាលាឬគគស ហើយត្រូវទទួលបានវិញនូវវិក័យប័ត្រត្រឹមត្រូវ។ | | | | | | | | | | | | |
| ៨. សិស្សជាអ្នកកត់ត្រាចំនួនម៉ោងបង្រៀនបន្ថែម និងបញ្ជូនកំណត់ត្រាទៅនាយកសាលាឬគគសដើម្បីបើកប្រាក់ឧបត្ថម្ភមកគ្រូបង្រៀនវិញ។ សាលារៀនត្រូវធ្វើរបាយការណ៍ចំណូល និងចំណាយនៅដំណាច់ឆ្នាំសិក្សា និងបិទផ្សាយជាសាធារណៈ។ | | | | | | | | | | | | |
| **សូចនាក ៨-៩** | | | | | | | | | | | | |
| ១. នាយកសាលាពិភាក្សាជាមួយគគស និងព្រមព្រៀងគ្នាអនុវត្តកម្មវិធីនេះ។ ការអនុវត្តត្រូវប្រព្រឹត្តទៅតាមការណែនាំមាននៅក្នុងសៀវភៅនេះ។ | | | | | | | | | | | | |
| ២. សិស្សរៀនធ្វើកិច្ចការជាគម្រោង តាមការរៀនបែបចម្រុះមុខវិជ្ជា។ សិស្សនឹងមានសមត្ថភាពរកចំណូល រកចំណូលបាន និងអាចសន្សំលុយទៅរៀននៅមហាវិទ្យាល័យ។ សកម្មភាពលម្អិតមានដូចខាងក្រោម៖<br>ក. សាលារៀនប្រជុំជាមួយសិស្ស ណែនាំពីការរៀនធ្វើកិច្ចការជាគម្រោងតាមការណែនាំរបស់ក្រសួង កត់ឈ្មោះសិស្ស និងមុខបំណិនសិស្សម្នាក់ៗចង់រៀននិងអនុវត្ត ហើយសាលារៀនបញ្ជូនឈ្មោះសិស្សមកក្រសួង។<br>ខ. នាយកសាលារៀន ដែលបានរៀនសូត្រពីមហាវិទ្យាល័យអប់រំ ធ្វើកិច្ចការជាមួយគ្រូបង្រៀនដែលបានរៀនសូត្រពីសាកលវិទ្យាល័យ បង្រៀនសិស្សពីការរៀបចំគម្រោងវិនិយោគ តាមមុខបំណិនសិស្សចង់រៀន បន្ទាប់សិស្សម្នាក់ៗរៀបចំគម្រោងវិនិយោគរបស់គ្រួសារ បូកសរុបទិន្នន័យនិងព័ត៌មានជាក្រុមសិស្សតាមភូមិ បញ្ជូនមកសាលារៀន ទីបញ្ចប់សាលារៀនត្រូវបូកសរុបគម្រោងវិនិយោគទាំងអស់ជាគម្រោងវិនិយោគរបស់សាលារៀន<br>គ. គ្រូបង្រៀន និងនាយកសាលារៀន បង្រៀនសិស្សពីបំណិន ទាំងទ្រឹស្តីនិងការអនុវត្ត សិស្សសិក្សាទ្រឹស្តី និងហាត់អនុវត្តមុខបំណិននៅសាលារៀន ព្រមទាំងសិក្សាខ្លឹមសារមុខវិជ្ជា បន្សុីគ្នាទៅនឹងដំណាក់ការនៃការរៀនសូត្រមុខបំណិន ដូចមាននៅក្នុងការណែនាំ<br>ឃ. សិស្សបន្តរៀនសូត្រ និងអនុវត្តមុខបំណិននៅតាមផ្ទះ ឬកសិដ្ឋានសម្រាប់បំណិនកសិកម្ម ឬនៅរោងជាងសម្រាប់បំណិនកមន្តសាលកម្ម។ សិស្សរៀនកត់ត្រាទិន្នន័យ និងព័ត៌មាន ជួបពិភាក្សាក្នុងក្រុម វិភាគការរីកចម្រើននិងបញ្ហាជួបប្រទះ ស្វែងរកសកម្មភាពជាដំណោះស្រាយបញ្ហា។ នាយកសាលានិងគ្រូបង្រៀនចុះជួយសិស្សតាមផ្ទះសិស្ស ពិសេសសិស្សមានជួបបញ្ហាក្នុងការរៀនសូត្រនិងអនុវត្ត។ សិស្សបូក | | | | | | | | | | | | |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| *សរុបលទ្ធផលការរៀនសូត្រ និងយកមកបង្ហាញនៅសាលារៀន តាមត្រីមាស ឆមាស និងចុងឆ្នាំ*<br>*ង. សាលារៀនបូកសរុបលទ្ធផលត្រីមាស ឆមាស និងចុងឆ្នាំ ហើយបង្ហាញលទ្ធផលទៅសហគមន៍ នៅពេលបូកសរុបលទ្ធផលនីមួយៗ ហើយបន្តសកម្មភាពវដ្តវិលជុំប្រចាំឆ្នាំឡើងវិញ។* | | | | | | | | | | | | |
| **សូចនាក ១០-១១** | | | | | | | | | | | | |
| *១. ការប្រកួតប្រជែងនេះមានរៀបរាប់នៅក្នុងស្តង់ដាទី១ម្តងរួចហើយ។ ការបញ្ចូលសកម្មភាពដដែលនេះ នៅក្នុងស្តង់ដាទី២ គឺជាការបញ្ជាក់នូវភាពសំខាន់ចាំបាច់ដែលមិនអាចខ្វះបាននៃសូចនាករនេះ ដូចនេះនាយកសាលារៀន និងគ្រូបង្រៀនត្រូវរៀបចំសកម្មភាពនេះជាប់ជាបន្ត និងទៀងទាត់រាល់ខែឬពីរខែម្តង។ បើសិស្សអាចអានតាមល្បឿនកំណត់ក្នុងមួយនាទី សិស្សនឹងអាចយល់អត្ថបទបាន សិស្សនឹងអាចរៀនគ្រប់មុខវិជ្ជាបាន សិស្សនឹងអាចបណ្តុះសមត្ថភាពគិត វិភាគ និងសរសេរបាន ហើយទីបញ្ចប់សិស្សអាចរៀនទៅមហាវិទ្យាល័យបាន។ គ្រូបង្រៀនគប្បីចងចាំនិងយល់ថា ការអានឮៗជាការចាំបាច់ ព្រោះវាជួយខួរក្បាលសិស្សឱ្យឮនិងចងចាំនូវពាក្យដែលគេអាន។ បើទោះជាអានអត្ថបទដដែលៗច្រើនដងក៏ដោយ វាជួយឱ្យការអានកាន់តែលឿន នោះជាការចាំបាច់។* | | | | | | | | | | | | |
| **សូចនាក ១២-១៤** | | | | | | | | | | | | |
| *១. សិស្សជាអ្នកកត់ត្រាសិស្សអវត្តមាន គ្រូអវត្តមាន គ្រូអវត្តមានតែមានគ្រូជំនួស សាលាបិទទ្វារដែលមិនមែនជាថ្ងៃឈប់កំណត់ដោយរដ្ឋ* | | | | | | | | | | | | |
| *២. សាលារៀនមិនត្រូវអនុញ្ញាតឱ្យមានការរៀបចំពិធីក្នុងសាលារៀន ឬមួយមានការផ្សាយពាណិជ្ជកម្មក្នុងសាលារៀន ឬមួយយកសិស្សទៅចូលរួមពិធីណាមួយដែលនាំឱ្យខាតបង់ម៉ោងសិក្សារៀនសូត្ររបស់សិស្ស។ ក្នុងករណីណាដែលមានការបង្ខំឱ្យធ្វើនូវរឿងរ៉ាវទាំងអស់នេះ គគសនិងនាយកសាលា រាយការណ៍មកក្រសួង និងអាជ្ញាធរមានសមត្ថកិច្ចសម្រាប់ធ្វើអន្តរាគមន៍ ហើយសាលារៀនមិនបាច់រវល់ជាមួយសំណើទាំងនោះទេ គឺនៅបន្តដំណើរការសាលារៀនដដែល។* | | | | | | | | | | | | |
| *៣. នាយកសាលាត្រូវកត់ត្រាព័ត៌មានទាំងនេះ ហើយបូកសរុប និងយកមកពិភាក្សានៅសិក្ខាសាលារៀងរាល់ឆ្នាំ។* | | | | | | | | | | | | |
| **សូចនាក ១៥** | | | | | | | | | | | | |
| *១. សាលារៀនប្រមូលទិន្នន័យ ពីហិង្សាក្នុងគ្រួសារ តាមថ្នាក់រៀន និងក្នុងសាលារៀនតាមគំរូ នៅក្នុងសៀវភៅនេះ។* | | | | | | | | | | | | |
| *២. នាយកសាលា ជាមួយគគស គ្រូបង្រៀន និងសិស្ស រៀបចំផែនការបំបាត់អំពើហឹង្សានេះ តាមគំរូមាននៅក្នុងសៀវភៅនេះ។ គ្រូសិក្សាពីករណីសិស្សមានហិង្សានៅផ្ទះ យកលទ្ធផលសិក្សាមកបង្ហាញនៅថ្នាក់រៀន និងសាលារៀន ហើយជួយសិស្សដោះស្រាយបញ្ហាហិង្សាជាមួយរដ្ឋអំណាច រួមផ្សំជាមួយការជួយសិស្សរៀនសូត្រទាន់ថ្នាក់។* | | | | | | | | | | | | |
| *៣. កត់ត្រានូវភាពរីកចម្រើន នៃការថយចុះអំពើហឹង្សានៅតាមផ្ទះ ក្នុងថ្នាក់រៀន និងសាលារៀន។ សម្រាប់ហិង្សាក្នុងថ្នាក់រៀនត្រូវបញ្ឈប់ជាបន្ទាន់ និងមិនអនុញ្ញាតឱ្យមានជាលើកទី២ឡើយ។ តំណាងសិស្សតាមថ្នាក់ត្រូវរាយការណ៍ជាបន្ទាន់ដល់នាយកសាលា ឬគគស* | | | | | | | | | | | | |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| *ប្រសិនគ្រូណាម្នាក់ប្រព្រឹត្តិចរិយាហិង្សាដល់សិស្ស។* | | | | | | | | | | | | |
| *៤. នាយកសាលាធានាថា មានការកត់ត្រានូវទិន្នន័យពីហិង្សា និងបញ្ចូលទៅក្នុងការប្រជុំប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំដើម្បីពិភាក្សាដោះស្រាយ។* | | | | | | | | | | | | |
| សូចនាក ១៦ | | | | | | | | | | | | |
| *១. ជាមួយការណែនាំពីសាកលវិទ្យាល័យ នាយសាលារៀបចំប្រជុំជាមួយសិស្ស ដើម្បីរៀបចំនូវកម្មវិធីមុខរបរសម្រាប់សិស្សម្នាក់ៗ តាមការណែនាំក្នុងសៀវភៅនេះ។* | | | | | | | | | | | | |
| *២. សិស្សម្នាក់ៗត្រូវសម្រេចចិត្តថាត្រូវទៅរៀនមុខជំនាញអ្វីនៅមហាវិទ្យាល័យ ទៅតាមកោសល្យរបស់ខ្លួន ជាមួយភាពខ្លាំងលើមុខវិជ្ជានៅមធ្យមសិក្សា និងចុះឈ្មោះជាមួយសាកលវិទ្យាល័យដែលខ្លួនមានបំណងប្រាថ្នាទៅរៀន។* | | | | | | | | | | | | |
| *៣. សាកលវិទ្យាល័យបន្តការជួយសិស្សអនុវត្តបំណិនកសិកម្ម ឬកម្មន្តសាលកម្មឱ្យបានត្រឹមត្រូវតាមបច្ចេកវិទ្យាទំនើប។* | | | | | | | | | | | | |
| **ស្តង់ដាទី៣ ភាពជាម្ចាស់នៃសាលារៀនសហគមន៍** | | | | | | | | | | | | |
| សូចនាក ១-៣ | | | | | | | | | | | | |
| *១. នាយកសាលារៀនរៀបចំប្រជុំបោះឆ្នោតជ្រើសរើសគណៈកម្មការគ្រប់គ្រងសាលារៀនតាមការណែនាំ និងបញ្ជូនបញ្ជីឈ្មោះទៅក្រុង ស្រុក ខណ្ឌដើម្បីអនុម័ត* | | | | | | | | | | | | |
| *២. គគសដឹកនាំការប្រជុំប្រចាំត្រីមាស ឆមាស និងឆ្នាំតាមការណែនាំក្នុងសៀវភៅ។ សិស្ស គ្រូបង្រៀន និងនាយកសាលារៀនពិភាក្សាគ្នាពីសារៈសំខាន់នៃ ទិន្នន័យ ព័ត៌មាន និងស្ថិតិ (តាមការណែនាំ) ចាប់ផ្តើមកត់ទិន្នន័យ និងព័ត៌មាន ទៅតាមសូចនាករ ទាំងអស់នៃស្តង់ដានីមួយៗ។ ប្រើប្រាស់ទិន្នន័យនិងព័ត៌មាន នៅក្នុងការប្រជុំប្រចាំខែ ពិនិត្យការអនុវត្តសកម្មភាព ប្រជុំប្រចាំត្រីមាសពិនិត្យការសម្រេចលទ្ធផលជាក្រុមគោលដៅត្រីមាស និងប្រជុំប្រចាំឆ្នាំពិនិត្យការសម្រេចលទ្ធផលជាក្រុមគោលដៅចុងឆ្នាំ។ ពេលប្រជុំនីមួយៗ ត្រូវរកឱ្យឃើញបញ្ហាដែលរាំងស្ទះការរៀនសូត្រ និងការបង្រៀន ហើយកំណត់សកម្មភាពជាក់ស្តែងច្បាស់លាស់សម្រាប់ដោះស្រាយបញ្ហា។* | | | | | | | | | | | | |
| *៣. គគសដឹកនាំការប្រជុំប្រែក្លាយគកសទៅជា ក្រុមប្រឹក្សាសាលារៀន នៅពេលណាដែលសាលារៀនមានការរីកចម្រើនបំពេញបាននូវស្តង់ដា សហគមន៍សាលារៀន ហើយមានសមាជិកសហគមន៍ ពិសេសអ្នកមានជាច្រើនស្ម័គ្រចិត្តចូលជាសមាជិកក្នុងក្រុមប្រឹក្សាសាលារៀន។* | | | | | | | | | | | | |
| សូចនាក ៤-៥ | | | | | | | | | | | | |
| *១. នាយកសាលារៀនបង្ហាញពីលទ្ធផលវាយតម្លៃ គ្រូបង្រៀននិងនាយកសាលារៀន ប្រចាំឆ្នាំដល់គគស ហើយគគសពិភាក្សាជាមួយនាយកសាលារៀន កំណត់រង្វាន់ត្រូវផ្តល់ជូនគ្រូបង្រៀនណា និងអនុម័តរបាយការណ៍វាយតម្លៃ* | | | | | | | | | | | | |
| *២. ដោយឡែកសម្រាប់នាយកសាលារៀន និងនាយករងសាលារៀន គឺគគស និងនាយកសាលារៀនត្រូវអនុវត្តការវាយតម្លៃតាមការណែនាំក្នុងសៀវភៅ ហើយចុងបញ្ចប់គគស* | | | | | | | | | | | | |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| សម្រេចអនុម័តការវាយតម្លៃ កំណត់ពិន្ទុវាយតម្លៃ និងរង្វាន់ត្រូវផ្តល់ឱ្យ | | | | | | | | | | | | |
| ៣. សាលារៀនត្រូវបញ្ជូនលទ្ធផលវាយតម្លៃ របស់គ្រូបង្រៀននិងនាយកសាលារៀន មកក្រសួងនៅដើមខែមករា រៀងរាល់ឆ្នាំ និងរាយការណ៍និងស្នើសុំឋានៈវិជ្ជាជីវៈជូនសាលារៀននិងនាយកសាលារៀននូវការអនុម័តរបស់ឯកឧត្តមរដ្ឋមន្ត្រី តាមការសម្រេចបានរបស់គ្រូបង្រៀន និងនាយកសាលារៀន។ ក្រសួងពិនិត្យនិងបូកសរុបលទ្ធផល ជាមួយនិងសំណើររបស់សាលារៀន និងរាយការណ៍ និងស្នើសុំឋានៈវិជ្ជាជីវៈដល់គ្រូបង្រៀន និងនាយកសាលារៀន។ | | | | | | | | | | | | |
| **សូចនាក ៦** | | | | | | | | | | | | |
| ១. នាយកសាលារៀននិងគគសរៀបចំ និងចុះសួរសុខទុក្ខសិស្សអវត្តមានដល់ផ្ទះជាប់ជាបន្ត ពិភាក្សាជាមួយមាតាបិតាសិស្ស កំណត់អនុវត្តសកម្មភាពដោះស្រាយបញ្ហា និងនាំសិស្សមករៀនវិញ។ | | | | | | | | | | | | |
| **សូចនាក ៧** | | | | | | | | | | | | |
| ១. នាយកសាលារៀននិងគគសឬកបស សម្របសម្រួលផលិតគម្រោងវិនិយោគរបស់សាលារៀន ដោយមានបញ្ជាក់មុខបំណិន និងបរិមាណចំណូលនៃមុខបំណិននីមួយៗនៅខែធ្នូឱ្យបានច្បាស់លាស់ សម្រាប់អនុវត្តសកម្មភាពបំណិនរកចំណូលឆ្នាំ២០២៣ | | | | | | | | | | | | |
| ២. គ្រោងសកម្មភាពនៅខែធ្នូ ដែលត្រូវចំណាយបន្ថែម មានដូចខាងក្រោម៖<br>ក. ការបង្រៀនបន្ថែមម៉ោងឱ្យបាន១៥ម៉ោងមួយថ្ងៃ (បឋម១២ម៉ោងមួយថ្ងៃ)<br>ខ. ការរៀបចំកសិដ្ឋានកសិកម្ម ឬរោងជាងនៅសាលារៀន និងអនុវត្តការរៀនសូត្របំណិនរកចំណូល<br>គ. ការរៀបចំថ្នាក់កុំព្យូទ័រ និងភាសាបរទេសដូចជា អង់គ្លេស ឬបារាំង ចិន ថៃ វៀតណាម។ល។<br>ឃ. ការរៀបចំថ្នាក់មត្តេយ្យសិក្សានៅក្នុងសាលាបឋមសិក្សា ឬមធ្យមសិក្សា<br>ង. ការរៀបចំកន្លែងលក់ដូរ អាហារដ្ឋាន និងភោជនីយដ្ឋាន ដែលជាទីតាំងរៀនសូត្របំណិនការងាររបស់សិស្ស<br>ច. ការរៀបចំកសិដ្ឋានឱ្យក្លាយជាទីតាំងទេសចរ ។ល។ | | | | | | | | | | | | |
| **សូចនាក ៨-១៣** | | | | | | | | | | | | |
| ១. នាយកសាលារៀនជាអ្នកសម្របសម្រួលរៀបចំនូវការប្រជុំ និងដាក់ស្នើសំណុំឯកសារទាំងអស់ខាងលើមក គគស ឬកបស ដើម្បីពិនិត្យ និងអនុម័ត | | | | | | | | | | | | |
| ២. នាយកសាលាធានានូវការបិទផ្សាយគ្រប់ទិន្នន័យ និងព័ត៌មានខាងលើជាសាធារណៈ និងទៀងទាត់តាមការកំណត់ | | | | | | | | | | | | |
| ៣. សាលារៀនចាប់ផ្តើម សរសេររបាយការណ៍ដឹកនាំសាលារៀន ដោយប្រើសំនួរដឹកនាំទាំង៨ តាមការណែនាំក្នុងសៀវភៅ | | | | | | | | | | | | |
| **សូចនាក ១៤** | | | | | | | | | | | | |
| ១. សិស្សនិងយុវជនមានតួនាទីសំខាន់ក្នុងកិច្ចការនេះ។ នាយកសាលារៀនរៀបចំនិងអនុវត្តផែនការរយៈពេល៣ឆ្នាំ ដាំដើមឈើតាមចំនួន ដែលធ្វើឱ្យទីធ្លាសាលារៀនគ្របដណ្តប់ | | | | | | | | | | | | |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| *ដោយម្លប់។ កិច្ចសហការណ៍ជាមួយក្រសួងពាក់ព័ន្ធធានានូវការមានកូនឈើមកដាំ ជៀសវាងប្រើលុយសាលារៀនទិញកូនឈើ។ នាយកសាលារៀនពិភាក្សាជាមួយសិស្ស និងព្រមព្រៀងគ្នាថា សិស្សត្រូវដាំដើមឈើនៅផ្ទះរបស់ខ្លួនប៉ុន្មានដើម ធានាថាផ្ទះសិស្សមានម្លប់គ្រប់គ្រាន់។ នាយកសាលាត្រូវយកទីធ្លាសាលារៀនដាំដំណាំជាបន្លែ គ្រប់ប្រភេទ ធ្វើឲ្យធ្លាសាលារៀន មានព័ណ៌បៃតង និងអាចយកផលិតផលធ្វើជាអាហារសម្រាប់សិស្សក្រីក្រហូបនៅសាលារៀន និងយកផលិតផលលក់ទៅទីផ្សារ ជាជាងដាំផ្កាដែលពុំមានប្រយោជន៍ដល់ការហូបចុក។* | | | | | | | | | | | | |
| *២. សាលារៀនធានា មិនមានធុងសំរាម និងមិនមានសំរាម នៅក្នុងសាលារៀនឬថ្នាក់រៀនឡើយ។ នាយកសាលារៀនពិភាក្សាជាមួយសិស្សធានាថា មិនត្រូវមានសំរាមនៅជុំវិញផ្ទះ ឬក្នុងភូមិឡើយ។ សិស្សរួមថ្នាក់ណាដែលឃើញថាមានសំរាមនៅផ្ទះនៃសិស្សនៅក្បែរខាង និងត្រូវមានការណែនាំគ្នា ឬមួយយកមកពិភាក្សានៅក្នុងថ្នាក់រៀន ឬសាលារៀនដើម្បីដោះស្រាយ។* | | | | | | | | | | | | |
| *៣. នាយកសាលាដាក់កិច្ចការឱ្យគ្រូបន្ទុកថ្នាក់ និងក្រុមប្រឹក្សាយុវជនតាមថ្នាក់ថែរក្សានូវសួនបន្លែ កសិដ្ឋានចិញ្ចឹមសត្វ រោងជាងកម្មន្តសាលកម្ម អគារសិក្សា សង្ហារឹមតាមថ្នាក់របស់ខ្លួន បន្ទប់អនាម័យ និងថែរក្សាសម្ភារៈបរិក្ខារវិទ្យាសស្ត្រ ឬបច្ចេកវិទ្យា ដោយរៀបចំកាលវិភាគសប្តាហ៍។* | | | | | | | | | | | | |
| **សូចនាក ១៥-១៦** | | | | | | | | | | | | |
| *១. សកម្មភាពរៀបចំកម្មវិធីបំណិនរកចំណូលមាននៅក្នុងស្តង់ដាទី២រួចហើយ តែខ្លឹមសារនៅក្នុងសូចនាករនេះជាការធានានូវការអនុវត្តជាប់ជាប្រចាំនូវកម្មវិធីដែលបានគ្រោងទុក។ នាយកសាលាទំនាក់ទំនងច្បាស់លាស់ជាមួយសាកលវិទ្យាល័យដៃគូ មន្ត្រីក្រសួងដែលមានតួនាទីជួយសាលារៀន និងមហាវិទ្យាល័យអប់រំក្នុងការអនុវត្តកម្មវិធីនេះ។ សាកលវិទ្យាល័យផ្តល់ជំនួយបច្ចេកទេសពីការអនុវត្តបំណិន។ មន្ត្រីក្រសួងធានាផ្តល់ប្រឹក្សាពីការគ្រប់គ្រងកម្មវិធីធានាដល់ដំណើរការមាននិរន្តរភាព។ មហាវិទ្យាល័យអប់រំអនុវត្តការបង្រៀនចម្រុះមុខវិជ្ជា។* | | | | | | | | | | | | |
| *២. នៅឆ្នាំណាមួយក្រោយពីការអនុវត្តម្មវិធីបំណើនរកចំណូល នាយកសាលានិងគគស ឬកបស ពិភាក្សាគ្នារៀបចំកម្មវិធីធានារ៉ាប់រងសង្គម និងអភិវឌ្ឍសមត្ថភាពមន្ត្រី។ មន្ត្រីក្រសួង និងទីប្រឹក្សាក្រសួងជួយសាលារៀនក្នុងការរៀបចំកម្មវិធីនេះ។ ការគ្រប់គ្រងនិងអនុវត្តកម្មវិធីនេះ ត្រូវមានដំណើរការតាមការណែនាំដែលមាននៅក្នុងសៀវភៅនេះ។* | | | | | | | | | | | | |
| **ស្តង់ដាទី៤ ដំណើរប្រតិបត្តិការសាលារៀន** | | | | | | | | | | | | |
| **សូចនាក ១-៣** | | | | | | | | | | | | |
| *១. ក្រោយការបញ្ចូលទិន្នន័យ ជាលទ្ធផលតេស្តស្តង់ដាដើមឆ្នាំសិក្សា ចូលក្នុងតារាងហើយ នាយកសាលារៀនសម្របសម្រួលរៀបចំ ផែនការសមិទ្ធកម្មសូចនាក គន្លឹះរយៈពេលមធ្យម៦ឆ្នាំ បន្ទាប់រៀបចំផែនការផលសម្រេចរយៈពេល៣ឆ្នាំ និងផែនការបង្រៀនរយៈពេល៣ឆ្នាំ និងចុងក្រោយផែនការកែលម្អសាលារៀនប្រចាំឆ្នាំតាមលំដាប់លំដោយ។* | | | | | | | | | | | | |
| *២. ចំណាំ៖ ចំពោះក្រុមគោលដៅ នៃសូចនាករណាមួយ ដែលមិនបានសម្រេច សាលារៀននឹងជំពាក់ក្រុមគោលដៅនោះ ហើយផ្តោតការអនុវត្តធានាថាចំនួនក្រុមគោលដៅដែលមិនបានសម្រេច យកទៅបូកបន្ថែមជាមួយ ក្រុមគោលដៅនៅឆ្នាំបន្ទាប់ ហើយអនុវត្តសូចនាក* | | | | | | | | | | | | |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| *ឬកិច្ចការនោះ ធានាសម្រេចឱ្យបាននៅឆ្នាំបន្ទាប់។* | | | | | | | | | | | | |
| *៣. សូចនាករដែលមិនបានសម្រេច និងការអនុវត្តសកម្មភាពដោះស្រាយបញ្ហា មានកត់ត្រានៅក្នុងកំណត់ហេតុប្រជុំ ប្រចាំខែ ត្រីមាស និងឆមាស និងចុងឆ្នាំ។ ព័ត៌មានទាំងនេះត្រូវសរសេរបញ្ចូលទៅក្នុងរបាយការប្រចាំឆ្នាំ ពិសេសរបាយការណ៍សំណួរដឹកនាំទាំង៨។* | | | | | | | | | | | | |
| **សូចនាក ៤-៧** | | | | | | | | | | | | |
| *១. នាយកសាលារៀនទទួលខុសត្រូវក្នុងការអនុវត្តតេស្តស្តង់ដាជាប់ជាប្រចាំ និងរក្សាគុណភាពឱ្យបានល្អ។ ក្រសួងផ្តល់សំណួរតេស្តស្តង់ដាដល់សាលារៀន ដើម្បីរក្សាកម្រិតគុណភាពស្តង់ដាតែមួយទូទាំងប្រទេស។* | | | | | | | | | | | | |
| *២. គ្រូត្រូវយកលទ្ធផលតេស្តចុងខែនីមួយៗមកប្រើប្រាស់ ដោយពិភាក្សាជាមួយសិស្ស និងជួយណែនាំសិស្សម្នាក់ៗឱ្យរៀនតាមសមត្ថភាពខ្វះចន្លោះរបស់សិស្សម្នាក់ៗ។* | | | | | | | | | | | | |
| *៣. គ្រូទទួលបន្ទុកថ្នាក់ ជាមួយគ្រូមុខវិជ្ជាត្រូវប្រជុំពិនិត្យលទ្ធផលតេស្តស្តង់ដាប្រចាំត្រីមាស ដោយស្វែងរកនូវសំណុំមេរៀនតាមមុខវិជ្ជាដែលសិស្សភាគច្រើនរៀនមិនចេះ កំណត់មូលហេតុនិងឧបសគ្គរាំងស្កាត់ការរៀនសូត្រ ដែលអាចមានដូចជាបណ្តាលមកពីការបង្រៀនមិនច្បាស់ ដោយសារសមត្ថភាពគ្រូឬមួយដោយការមិនទទួលខុសត្រូវរបស់គ្រូ មកពីការមិនសូវខិតខំរបស់សិស្សម្នាក់ៗ ដោយសារមូលហេតុសង្គមនិងសេដ្ឋកិច្ចរបស់សិស្សឬមួយដោយសារសមត្ថភាពបញ្ញាសិស្សទាបពេក (មកពីការអភិវឌ្ឍខួរក្បាលតាំងពីកុមារភាពមានការប៉ះទង្គិច) ហើយតើត្រូវកំណត់សកម្មភាពជួយសិស្សក្នុងថ្នាក់ ឬសិស្សម្នាក់ៗ តាមមេរៀននីមួយៗ។* | | | | | | | | | | | | |
| *៤. គ្រូទទួទលបន្ទុកថ្នាក់ចងក្រងលទ្ធផលពីការប្រជុំ បញ្ជូនទៅនាយកសាលារៀន ហើយនាយកសាលារៀនសរុបព័ត៌មានពីគ្រូបន្ទុកថ្នាក់ទាំងអស់ ជារបាយការណ៍សម្រាប់ការប្រជុំត្រីមាសជាមួយគគសដើម្បីដោះស្រាយ។* | | | | | | | | | | | | |
| *៥. នាយកសាលារៀនផលិត របាយការណ៍ពីការរីកចម្រើនការអនុវត្តផែនការកែលម្អសាលារៀនប្រចាំឆ្នាំ និងរបាយការណ៍វិភាគពីការបង្រៀននិងការសិក្សារៀនសូត្ររបស់សិស្ស។* | | | | | | | | | | | | |
| **សូចនាក ៨-១១** | | | | | | | | | | | | |
| *១. នាយកសាលារៀនពិភាក្សាជាមួយគ្រូបង្រៀនទាំងអស់ និងរៀបចំជាផែនការសម្រាប់គ្រូបង្រៀនចូលរួមរៀនសូត្រវគ្គលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន។* | | | | | | | | | | | | |
| *២. គ្រូបង្រៀនចូលរួមរៀនវគ្គលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន អនុវត្តកិច្ចការបានទទួលពីវគ្គ និងធានាសម្រេចបាននូវស្តង់ដាទី២។* | | | | | | | | | | | | |
| *៣. គ្រូបង្រៀនរៀបចំកិច្ចសន្យាលទ្ធផលប្រចាំឆ្នាំ និងផែនការអភិវឌ្ឍសមត្ថភាពរបស់ខ្លួន។ គ្រូបង្រៀនចូលរួមអនុវត្តការវាយតម្លៃពាក់កណ្តាលឆ្នាំ និងចុងឆ្នាំតាម ការណែនាំ។* | | | | | | | | | | | | |
| *៤. នាយកសាលារៀនអនុវត្តកិច្ចការអធិការកិច្ចផ្ទៃក្នុង ទៅតាមការកំណត់ក្នុងកិច្ចសន្យាលទ្ធផលប្រចាំឆ្នាំរបស់គ្រូបង្រៀន។ ការធ្វើអធិការកិច្ចផ្ទៃក្នុងមានវត្ថុបំណងជួយគ្រូអនុវត្ត* | | | | | | | | | | | | |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| *ការងាររបស់ខ្លួន មិនមែនមានបំណងស្វែងរកកំហុសរបស់គ្រូ និងបន្ទោសគ្រូបង្រៀននោះទេ។ ដូចគ្នានឹងការធ្វើអធិការកិច្ចពីថ្នាក់ក្រោមជាតិ ឬថ្នាក់ជាតិ ដែលមានបំណងជួយដល់ការកសាងសមត្ថភាពនិងលើកទឹកចិត្តគ្រូបង្រៀន ជាជាងការស្វែងរកកំហុសនិងស្តីបន្ទោស។ ប្រសិនមានអធិការណាម្នាក់ដែលអនុវត្តអធិការកិច្ចបែបស្វែងរកកំហុស នាយកសាលារៀនមានសិទ្ធិនិយាយជាមួយអធិការនោះថាការអនុវត្តកិច្ចការនេះគឺខុសវត្ថុបំណង ហើយ ត្រូវកែប្រែ បើមិនដូច្នោះទេ នាយកសាលារៀន និងគគសមិនអនុញ្ញាតឱ្យធ្វើបន្តទៀតឡើយ។* | | | | | | | | | | | | |
| សូចនាក ១២ | | | | | | | | | | | | |
| *១. លទ្ធផលតេស្តស្តង់ដាចុងឆ្នាំត្រូវបូកសរុបចូលក្នុងតារាងកម្រិតសិស្សម្នាក់ៗ ថ្នាក់រៀននីមួយៗ និងសាលារៀនទាំងមូល។ នៅកម្រិតថ្នាក់រៀន គ្រូទទួលបន្ទុកថ្នាក់រៀបចំការប្រជុំកម្រិតថ្នាក់រៀន ពិនិត្យលទ្ធផលសិក្សារបស់សិស្ស និងពិភាក្សារកមូលហេតុដែលនៅសេសសល់ចុងឆ្នាំ។ ការពិនិត្យពិភាក្សាខ្លឹមសារគឺមានលំនាំដូចគ្នានឹងការប្រជុំប្រចាំត្រីមាសដែរ។ គ្រូទទួលបន្ទុកថ្នាក់បញ្ជូនរបាយការណ៍ប្រជុំប្រចាំឆ្នាំមកនាយកសាលារៀន។ នាយករងទទួលបន្ទុកបច្ចេកទេសបូកសរុបលទ្ធផលរបាយការណ៍ពីគ្រូទទួលបន្ទុកថ្នាក់ទាំងអស់ចូលក្នុងរបាយការណ៍សរុបរបស់សាលារៀន និងជូនទៅនាយកសាលារៀន និងគគស។* | | | | | | | | | | | | |
| *២. នាយកសាលាដឹកនាំការប្រជុំស្វ័យវាយតម្លៃសាលារៀនចុងឆ្នាំ ដោយប្រើប្រាស់របាយការណ៍ពីការរីកចម្រើនការអនុវត្តផែនការកែលម្អសាលារៀន និងរបាយការណ៍វិភាគពីការបង្រៀននិងសិក្សារៀនសូត្ររបស់សិស្ស។ ចុងបញ្ចប់នាយកសាលារៀនបូកសរុបផ្តល់ពិន្ទុដល់ស្តង់ដា និងសូចនាករនីមួយៗ និងសរុបពិន្ទុស្តង់ដាសហគមន៍សាលារៀនសម្រាប់ឆ្នាំ និងជូនទៅគគស ដើម្បីពិនិត្យនិងអនុម័ត។* | | | | | | | | | | | | |
| សូចនាក ១៣ | | | | | | | | | | | | |
| *១. សកម្មភាពសម្រាប់សូចនាករនេះមានរៀបរាប់នៅខាងលើហើយ ហើយសកម្មភាពសម្រាប់សូចនាករនេះ ធានាអនុវត្តតាមថ្ងៃដែលបានគ្រោង ឱ្យក្លាយជាវប្បធម៌ប្រកួតប្រជែង ជាមួយនឹងការអនុវត្តទិវាជាតិអំណាន មានលក្ខណៈទ្រង់ទ្រាយធំ ដែលជាការប្រកួតកម្រិតរាជធានី ឬខេត្ត និងកម្រិតជាតិ។ សិស្សដែលចូលរួមប្រកួតត្រូវតែជាសិស្សដែលបានជ្រើសរើសតាមរូមមន្តណែនាំពីក្រសួង ជៀសវាងជ្រើសរើសយកតែសិស្សពូកែមកប្រកួត។ ការជ្រើសរើសសិស្សគឺអនុវត្តតាមរបៀបចាប់ឆ្នោត និងតាមចំនួនសិស្សកំណត់ដោយក្រសួង សម្រាប់ការប្រកួតកម្រិតជាតិ និងតាមការកំណត់របស់រាជធានី ខេត្ត សម្រាប់ការប្រកួតកម្រិតរាជធានីខេត្ត។ ការអនុវត្តបែបនេះតម្រូវឲ្យសាលារៀននីមួយៗ ត្រូវប្រឹងប្រែងជួយសិស្សជាប់ជាប្រចាំទាំងលើល្បឿនអំណាន រហូតសិស្សភាគច្រើនមានសមត្ថភាពអានតាមស្តង់ដាពាក្យក្នុងមួយនាទី ឬលឿនជាងស្តង់ដា និងក៏ដូចជាគណិតវិទ្យា ដែលបញ្ជាក់ពីល្បឿននៃការគិតលេខ ដែលមានកម្រិតខ្ពស់។* | | | | | | | | | | | | |
| សូចនាក ១៤ | | | | | | | | | | | | |
| *១. សាលារៀនត្រូវណែនាំសិស្សអនុវត្តការគ្រប់គ្រងទិន្នន័យគ្រប់ប្រភេទកម្រិតថ្នាក់រៀន និងកម្រិតសាលារៀន។* | | | | | | | | | | | | |
| *២. សាលារៀនត្រូវមានមន្ត្រីម្នាក់ទទួលខុសត្រូវលើប្រព័ន្ធទិន្នន័យ និងព័ត៌មាន ដោយប្រើបច្ចេកវិទ្យា។ ប្រមូល ចងក្រង វិភាគ និងបញ្ជូនទិន្នន័យមកក្រសួងទៀងទាត់តាមកាលកំណត់។* | | | | | | | | | | | | |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | | |
| *៣. នាយកសាលារៀនចូលរួមរៀនសូត្រពីការគ្រប់គ្រងទិន្នន័យ ក្នុងវគ្គបង្កើនគុណវុឌ្ឍិនាយកសាលារៀន។ នាយកសាលារៀនអនុវត្តការប្រើប្រាស់ទិន្នន័យព័ត៌មាន និងកសាងចំណេះដឹងជាពិសោធន៍សម្រាប់ឆ្លើយតបទៅនឹងតម្រូវការគ្រប់ប្រភេទអតិថិជនដើម្បីជាប្រយោជន៍ដល់ការអភិវឌ្ឍសាលារៀន និងសហគមន៍។* | | | | | | | | | | | | |
| សូចនាក ១៥-១៦ | | | | | | | | | | | | |
| *១. នាយកសាលារៀនរៀបចំការប្រជុំ ជាការបង្រៀននិងរៀនសូត្រ ពីការអប់រំមាតាបិតាសិស្ស ពីសមត្ថភាពចិត្តសង្គម និងរបៀបថែទាំកូន។ ខ្លឹមសារនិងរបៀបប្រជុំពីការថែទាំកូនមាននៅក្នុងសៀវភៅនេះ ហើយនាយកសាលាបន្តអនុវត្តតាមការណែនាំនេះ។ បរិស្ថានដែលសិស្សរស់នៅ ទាំងនៅផ្ទះនិងនៅសាលារៀន ត្រូវតែមានសភាពដូចគ្នា នោះទើបអាចជួយសិស្សឱ្យបណ្ដុះបាននូវសមត្ថភាពចិត្តនិងសង្គមដែលគេត្រូវការ។* | | | | | | | | | | | | |
| *២. នាយកសាលានិងគ្រូបង្រៀនអនុវត្តការស្វែងរកសិស្ស ដែលមានភាពខ្សោយគំហើញចំនួន ...........នាក់ និងខ្សោយស្ដាប់ចំនួន ........នាក់។ សិស្សដែលមានបញ្ហាណាមួយនៃបញ្ហាទាំងពីរ គឺមិនអាចរៀនបានឡើយ។ គ្រូបង្រៀនអញ្ជើញមាតាបិតានៃសិស្សទាំងនេះ មកសាលារៀនពិភាក្សាជាមួយគាត់ និងធានាថាគាត់យកកូនទៅកន្លែងសេវាពិនិត្យភ្នែក ឬសេវាពិនិត្យត្រចៀក ដើម្បីកូនទទួលបាននូវវ៉ែនតាពាក់ ឬឧបករណ៍ស្ដាប់តាមកម្រិតនៃការខ្សោយគំហើញ ឬខ្សោយស្ដាប់។ ចំពោះគ្រួសារក្រីក្រសាលារៀនអាចជួយថវិកាសាលារៀនដល់គាត់សម្រាប់ទិញវ៉ែនតា ឬឧបករណ៍ស្ដាប់។ គ្រូបង្រៀនជម្រាបមាតាបិតា ត្រូវត្រឡប់មកផ្ដល់ព័ត៌មានដល់គ្រូវិញធានាថាសិស្សបានទទួលវ៉ែនតាពាក់ ឬឧបករណ៍ស្ដាប់។ គ្រូបង្រៀនសរុបទិន្នន័យទាំងនេះបញ្ជូនមកនាយកសាលា។* | | | | | | | | | | | | |
| *៣. នាយកសាលារៀនចាត់តំណាងសិស្សចងក្រងព័ត៌មានទាំងនេះ ដើម្បីបញ្ចូលក្នុងរបាយការណ៍ឆ្នាំ និងបិទព័ត៌មានផ្សព្វផ្សាយដល់សាធារណៈពីសកម្មភាពសង្គមដែលសាលារៀនបានអនុវត្ត ជាផ្នែកនៃការថែរក្សាគ្នានៅក្នុងសហគមន៍។* | | | | | | | | | | | | |
| *៤. សាលារៀនអប់រំសិស្សនិងមាតាបិតាពីច្បាប់ចរាចរណ៍ ផ្ដោតលើចរិយាគ្រោះថ្នាក់ពេលបើកបរ និងចរិយាសំខាន់ៗដែលត្រូវប្រតិបត្តិពេលបើកបរ និងបញ្ជាក់នូវការសម្រេចចិត្តជាមួយមាតាបិតានិសិស្សថានឹងគោរពដោយហ្មត់ចត់នូវច្បាប់ចរាចរព្រមទាំងចរិយាដែលត្រូវប្រតិបត្តិ ជាមួយការសន្យាថាសហគមន៍នឹងចម្រេចបាន នូវសុវត្ថិភាពចរាចរណ៍ក្នុងសហគមន៍។* | | | | | | | | | | | | |
| *៥. សាលារៀនត្រូវផ្ដល់ទិន្នន័យពីកុមារ សិស្ស សាលារៀន ថ្នាក់រៀន និងគ្រូបង្រៀននៅតំបន់កោះ មកក្រសួងនៅខែធ្នូ ឆ្នាំ២០២២។ ក្រសួងវិភាគទិន្នន័យទទួលបាន កំណត់អាទិភាពនៃការជួយ និងដាក់ស្នើសុំការអនុម័តពីឯ.ឧ រដ្ឋមន្ត្រី។* | | | | | | | | | | | | |
| **ស្តង់ដាទី៥ គណនេយ្យភាពថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ** | | | | | | | | | | | | |
| សូចនាក ១-២ | | | | | | | | | | | | |
| *១. នៅក្នុងវគ្គលើកកម្ពស់គុណវុឌ្ឍិនាយកសារៀន និងគ្រូបង្រៀន សិក្ខាកាមពិភាក្សាជាមួយមហាវិទ្យាល័យអប់រំ ពីចំនួនដងដែលត្រូវទទួលការបង្វិកពីគ្រូបង្រៀននៃមហាវិទ្យាល័យសម្រាប់បញ្ចូលក្នុងផែនការបង្វឹក។ គ្រូបង្រៀននៃមហាវិទ្យាល័យអប់រំគឺ* | | | | | | | | | | | | |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| *ជានាយកសាលារៀន ឬគ្រូបង្រៀនដែលឈរជើងធ្វើការនៅតាមសាលារៀន ដែលមានស្តង់ដាសហគមន៍សាលារៀននៅក្នុងរាជធានីខេត្ត ឬ ក្រុង ស្រុក ជាមួយគ្នា។* | | | | | | | | | | | | |
| *២. ខ្លឹមសារជួយបង្វិក ត្រូវផ្តោតលើការដឹកនាំនិងគ្រប់គ្រង សមត្ថភាពមុខវិជ្ជា (ចំណេះដឹងនិងបំណិនមុខវិជ្ជា) សមត្ថភាពអនុវត្តមុខវិជ្ជានៅក្នុងជីវិតជាក់ស្តែង និងការរកចំណូល (ជាការរៀនចម្រុះមុខវិជ្ជា) និងសមត្ថភាពចិត្តនិងសង្គម)។ ការបង្វិកអាចជាការបង្រៀនឱ្យមើលពីគ្រូបង្វិក ឬការបង្រៀនឱ្យមើលពីអ្នកត្រូវទទួលការបង្វិក ការរៀបចំសំណួរតេស្ត ឬការឆ្លើយសំណួរតេស្តដែលមានកម្រិតងាយស្រួល មធ្យម និងលំបាក និងកម្រិតអន្តរជាតិ ល្បិចបង្រៀនភាសាខ្មែរ និងគណិតវិទ្យា វិធីសាស្ត្រជួយសិស្សជួបការលំបាកក្នុងការរៀនសូត្រ របៀបគ្រប់គ្រងនិងប្រើប្រាស់ទិន្នន័យ របៀបទំនាក់ទំនង ការធ្វើផែនការ ឬការធ្វើតេស្តស្តង់ដា ការសរសេរកិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំ និងការវាយតម្លៃពាក់កណ្តាល និងចុងឆ្នាំ។ល។* | | | | | | | | | | | | |
| **សូចនាក ៣-៥** | | | | | | | | | | | | |
| *១. មន្ត្រីក្រសួងដែលទទួលខុសត្រូវតាមតំបន់ មន្ទីរអប់រំ និងការិយាល័យអប់រំស្រុក ត្រូវកំណត់នូវការប្តេជ្ញាចិត្តជួយសាលារៀន ដែលបញ្ជាក់ដោយ ចំនួនដងចុះបេសកកម្មគាំទ្រដល់សាលារៀននៅក្នុងផែនការរបស់ខ្លួន។ បេសកកម្មគាំទ្រ ត្រូវមានចំនួនពីរដងក្នុងមួយឆ្នាំ។* | | | | | | | | | | | | |
| *២. ការចុះបេសកកម្មគាំទ្រគឺត្រូវប្រតិបត្តិតាមការណែនាំមាននៅក្នុងសៀវភៅនេះ។* | | | | | | | | | | | | |
| *៣. ក្រសួងអនុវត្តការចុះបេសកកម្មគាំទ្រជាអនុវិស័យ ឬចម្រុះអនុវិស័យទាំងបី។ គោលបំណងនៃការចុះចម្រុះវិស័យ គឺស្វែងយល់ និងរៀនសូត្រពីមន្ទីរអប់រំ ការិយាល័យអប់រំស្រុក សហគមន៍សាលារៀន ប្រជាជន ពីអ្វីដែលរីកចម្រើន ឧបសគ្គ និងការរាំងស្ទះ និងកំណត់ដំណោះស្រាយដែលត្រូវធ្វើដោយក្រសួង មន្ទីរអប់រំ ការិយាល័យអប់រំស្រុក និងសហគមន៍សាលារៀន។ ការរកឃើញទាំងប៉ុន្មាន ក្រុមបេសកកម្មគាំទ្ររាយការណ៍នៅចុងចប់ នៃបេសកកម្មដល់ថ្នាក់ក្រោមជាតិ និងសហគមន៍សាលារៀន។* | | | | | | | | | | | | |
| **សូចនាក ៦** | | | | | | | | | | | | |
| *១. សកម្មភាពនៃកម្មវិធីនេះមានរៀបរាប់នៅខាងលើហើយ  សូចនាករនេះគឺជាការវាយតម្លៃចុងឆ្នាំថាកម្មវិធីបានបំពេញស្តង់ដាកម្មវិធីហើយឬនៅ* | | | | | | | | | | | | |
| *២. ការកឃើញពីការវាយតម្លៃ នាំឱ្យមានការស្វែងយល់ ជួយដល់ការសម្រេចចិត្តថា ត្រូវពង្រីកកម្មវិធីលើមុខបំណិនណា ការប្រើប្រាស់ទុនប៉ុន្មានសម្រាប់ពង្រីកកម្មវិធីជាមួយការសន្សំប្រាក់របស់សិស្ស គ្រូបង្រៀន នាយកសាលារៀន សាលារៀន និងសហគមន៍ និងការឈានឆ្ពោះទៅរកការបង្កើតកម្មវិធីធានារ៉ាប់រងសង្គមនិងអភិវឌ្ឍសមត្ថភាពមន្ត្រី* | | | | | | | | | | | | |
| *៣. សកម្មភាពនេះជាការអនុវត្តនូវយុទ្ធសាស្ត្រសហគមន៍សាលារៀន និងជាការអនុវត្តនូវគុណតម្លៃមួយដែលបានព្រមព្រៀងគ្នាក្នុងសហគមន៍។* | | | | | | | | | | | | |
| **សូចនាក ៧-៩** | | | | | | | | | | | | |
| *១. នាយកសាលា និងគគស ឬកបសប្រើវិធានការបំពេញតម្រូវការខ្វះគ្រូបង្រៀន .............នាក់ តាមវិធី៣យ៉ាង៖* | | | | | | | | | | | | |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| *ក. សហការជាមួយថ្នាក់ស្រុក និងមានការព្រមព្រៀងពីថ្នាក់ខេត្តផ្ទេរគ្រូ ពីសាលារៀនលើសគ្រូនៅក្បែរ មកបង្រៀននៅសាលារៀនខ្វះគ្រូ*<br>*ខ. នាយកសាលារៀនពិភាក្សាជាមួយមហាវិទ្យាល័យអប់រំ លើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន ដែលកំពុងបង្រៀនខុសមុខវិជ្ជាឱ្យយកមុខវិជ្ជាដែលកំពុងបង្រៀនខុសជាមុខវិជ្ជាឯកទេសវិញ និង*<br>*គ. ពិភាក្សាជាមួយសិស្ស ដែលមាននិទ្ទេសរៀនសូត្រល្អប្រសើរ និងដែលមានបំណងប្រាថ្នាធ្វើជាគ្រូបង្រៀន បញ្ជូនសិស្សនោះមករៀនធ្វើជាគ្រូបង្រៀន និងទទួលយកគេជាគ្រូកិច្ចសន្យាទៅបង្រៀននៅសាលារៀនរបស់គេវិញ។* | | | | | | | | | | | | |
| *២. បើរបៀបទាំង៣ខាងលើនេះនៅតែមិនអាចដោះស្រាយបញ្ហាខ្វះគ្រូទៀត នាយកសាលារៀនយកទិន្នន័យទាំងនេះ មកចែករំលែកនៅវគ្គលើកកម្ពស់គុណវុឌ្ឍិនាយកសាលារៀន និងសិក្ខាសាលាយុទ្ធសាស្ត្រសហគមន៍សាលារៀន ដើម្បីពិភាក្សាដោះស្រាយកម្រិតជាតិ។ ដូចគ្នានេះដែរចំពោកង្វះខាតនាយកសាលារៀន ឬនាយករង។* | | | | | | | | | | | | |
| *៣. នាយកសាលារៀនបញ្ជូនព័ត៌មាននៃសូចនាករទាំង៩ មកក្រសួង ហើយក្រសួងនឹងផលិតនូវកាតរបាយការណ៍សាលារៀនដោយមានបញ្ជាក់ស្ថានភាពនៃ សូចនាករនីមួយៗដោយប្រៀបធៀបរវាង សាលារៀនខ្ញុំ ស្រុកខ្ញុំ ខេត្តខ្ញុំ និងប្រទេសខ្ញុំ។ ក្រសួងនឹងបញ្ជូនកាតរបាយការណ៍នេះមកសាលារៀនវិញ ដើម្បីផ្សព្វផ្សាយជាសាធារណៈ។ កាតរបាយការណ៍នេះបង្ហាញនូវគណនេយ្យភាព ដែលបានកសាងនៅកម្រិតសហគមន៍សាលារៀន កម្រិតស្រុក កម្រិតរាជធានី ខេត្តនិងកម្រិតក្រសួង។* | | | | | | | | | | | | |
| | | | | | | | | | | | | |

**កិច្ចការត្រូវអនុវត្តដើម្បីសម្រេចលទ្ធផលសិក្សារំពឹងទុក៖**

*ក្រោយពីបញ្ចប់ការសិក្សាមុខវិជ្ជានេះដោយជោគជ័យអ្នកសិក្សានឹង៖*

កិច្ចការទី ១៖រៀបចំផែនការសាលារៀនរយៈខ្លី មធ្យម និងវែង

កិច្ចការទី ២៖រៀបចំផែនការសម្រាប់គ្រូម្នាក់ៗដើម្បីឲ្យឆ្លើយតបជាមួយផែនការសាលារៀន

កិច្ចការទី ៣៖ រៀបចំលំហូរនៃការគិតនិងធ្វើផែនការ៦ឆ្នាំ ៣ឆ្នាំ និង១ឆ្នាំ

កិច្ចការទី ៤៖របាយការណ៍កសាងផែនការថ្នាក់រៀនប្រចាំឆ្នាំ

កិច្ចការទី ៥៖ របាយការណ៍រៀបចំផែនការថ្នាក់រៀន និងផែនការសិក្សារៀនសូត្រសិស្សម្នាក់ៗ

# សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

## មហាវិទ្យាល័យអប់រំផ្តល់ការបណ្តុះបណ្តាលពីកម្រិតវិញ្ញាបនបត្រ ដល់បណ្ឌិតដូចខាងក្រោម៖

- វិញ្ញាបនបត្រអប់រំកុមារតូច
- វិញ្ញាបនបត្រអប់រំបឋមសិក្សា

- បរិញ្ញាបត្រអប់រំ ឯកទេសសិក្សាអប់រំ
- បរិញ្ញាបត្រអប់រំ ឯកទេសគ្រប់គ្រង និងអភិវឌ្ឍឧត្តមសិក្សា
- បរិញ្ញាបត្រអប់រំ ឯកទេសអប់រំពេញមួយជីវិត
- បរិញ្ញាបត្រអប់រំ វិជ្ជាជីវៈគ្រូបង្រៀន ឯកទេស អក្សរសាស្ត្រខ្មែរ ប្រវត្តិវិទ្យា គណិតវិទ្យា គីមី រូបវិទ្យា និងជីវវិទ្យា
- បរិញ្ញាបត្រអប់រំ ឯកទេសគ្រប់គ្រងអប់រំ
- បរិញ្ញាបត្រអប់រំ ឯកទេសកម្មវិធីសិក្សានិងការបង្រៀនកម្រិតកុមារតូច

- បរិញ្ញាបត្រជាន់ខ្ពស់អប់រំ វិជ្ជាជីវៈគ្រូបង្រៀន ឯកទេស អក្សរសាស្ត្រខ្មែរ ប្រវត្តិវិទ្យា គណិតវិទ្យា គីមី រូបវិទ្យា និងជីវវិទ្យា
- បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសកម្មវិធីសិក្សា និងការបង្រៀន
- បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសសិក្សាអប់រំ
- បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសគ្រប់គ្រង និងអភិវឌ្ឍឧត្តមសិក្សា
- បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសអប់រំពេញមួយជីវិត

- បណ្ឌិតអប់រំ ឯកទេសគ្រប់គ្រងអប់រំ
- បណ្ឌិតអប់រំ ឯកទេសកម្មវិធីសិក្សា និងការបង្រៀន
- បណ្ឌិតអប់រំ ឯកទេសអភិវឌ្ឍការអប់រំ
- បណ្ឌិតអប់រំ ឯកទេសអភិវឌ្ឍធនធានមនុស្ស និងអប់រំពេញមួយជីវិត

**មហាវិទ្យាល័យអប់រំក៏មានផ្តល់សេវាប្រឹក្សាយោបល់ និងស្រាវជ្រាវអប់រំផងដែរ។**

សម្រាប់ព័ត៌មានបន្ថែម សូមស្កេនខាងក្រោម

www.facebook.com/rupp.edu.kh

www.rupp.edu.kh/fed/

Facebook Page
Faculty of Education